ឆ្នាំទី ៤ លេខ ១១

ខែ ទី ១ វិច្ឆិកា

ទស្សនាវដ្ដី

# មិត្តសាលាបាលី

ផ្សាយពេញ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

ព.ស. ២៤៩៧ ចេញរាល់ថ្ងៃទី ១ ខែ

គ.ស. ១៩៥៤ ប្រក្រតិទិនសុរិយគតិ




ប្រាសាទអង្គរវត្ត

សូមជម្រាបជូន

ក្នុងឆ្នាំ ១៩៥៥ ខាងមុខនេះ គណៈកម្មការទស្សនាវដ្ដីមិត្តសាលាបាលី នឹងចាត់ការទទួលបុះឈ្មោះរបស់មិត្តទាំងឡាយក្នុងការជាវទស្សនាវដ្ដីនេះ ដើម្បីជួយពិគ្រោះយោបល់ព្រះពុទ្ធសាសនាកុំឲ្យធ្លាក់ចុះដោយការសង្កត់សង្កិនខាងសេដ្ឋកិច្ចណាមួយ ៗ ប៉ុន្តែការពិតាគឺមិនយកយ៉ាងនិងពិល ដោយគួរជួនក្ដីគេលើកលមិត្តភាគច្រើនឲ្យយោបល់ ៗ

មន្ទីរចាត់ការនៅវត្តលង្កា ស្ត្រីតលេខ ៦ ក្រុងភ្នំពេញ

បណ្ណាធិការ ហួត-តាត

# មាតិការឿង


| | | | |
|---|---|---|---|
| | | ................ បរិយាយអំពីពាក្យហៅថាសាសនា | ទំព័រ ១ |
| មហា | សម-ម៉ន | ................ គួរឈប់ប្រកាន់វណ្ណៈ | " ៥ |
| លោក | សួន-សារិន្ទ | ................ សភាពនៃសត្វ | " ៩ |
| " | " | ................ នរកនៅឯណា ? | " ១០ |
| | | ................ ព្រះរាជដំណើរនៃព្រះករុណា | " ១៤ |
| លោក | យ៉ែន-សាភន់ | ................ ចិត្តសប្បុរសនឹងកតញ្ញូ | " ១៩ |
| លោក | ហ៊ាយ-ប៊ុគា | ................ សិល្បៈនឹងអតីតនៃព្រះរាជអាណាចក្រខ្មែរ | " ២១ |
| លោក | ដេង-ជ្រីវ | ................ បញ្ហាពោលអំពីមនុស្សស្បែកខ្មៅ | " ២៤ |
| ព្រះមហា | ទួត-ងឹម | ................ អសោកមហារាជ | " ២៤ |
| លោក | ហ៊ាយ-ប៊ុគា | ................ រឿងតុក្កតាធ្វើពីទងជាតិ | " ២៩ |
| | | ................ ប្រវត្តិខេត្តបាត់ដំបង | " ៣៣ |


មិត្តដែលបានអានទស្សនាវដ្ដីនេះរាប់ទុកជាបានជួយលើកដំកើង

សាសនា អក្សរសាស្ត្រ នឹង ព្រះមហាក្សត្រ របស់ខ្លួន

## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ ៤៥៛០០ | ១ ឆ្នាំ ៩០៛០០ | ១ ក្បាល ៩៛០០ | ៦ខែ ៥៥៛០០ | ១ឆ្នាំ ១០៥៛០០ | ១ក្បាល ១០៛០០ |

អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse:** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*



## ថ្ងៃចន្ទ ទី ៧ មិថុនា ឆ្នាំ ១៩៥៤ នៅស្ថាន វិទ្យុកម្ពុជា

### បរិយាយអំពីពាក្យហៅថា សាសនា

មុននឹងខ្ញុំពណ៌នាសេចក្ដីជូនលោក-អ្នកស្ដាប់ក្នុងពេលនេះ ខ្ញុំបាទដែលត្រូវទទួលសិទ្ធិមកថ្លែងនាស្ថានវិទ្យុកម្ពុជា, សូមឲ្យសុជនទាំងឡាយអភ័យដល់ខ្ញុំផងក្រែងលោសេចក្ដីបរិយាយនេះប៉ះពាល់ទៅលើគោលការណ៍ណាដែលពុំសមគួរដល់កាលៈទេសៈ ឬក៏ពុំស្របទៅតាមគោលដើមនៃសេចក្ដីបរិយាយ ដោយអ្នកនិពន្ធខ្ញុំស្រាវជ្រាវរកដើមនឹងចុងពុំប្រាកដ; យោបល់ទាំងការខុសឆ្គងខ្ញុំសូមផ្ញើលើលោក-អ្នកដែលមាននាមថាជានិពន្ធឯក សម្រាប់សាសនាឬក៏ផ្ទុំលោក ។

អស់លោកទាំងឡាយ! ពាក្យហៅថាសាសនា បើតាមលក្ខណៈសព្វដើមដែលយើងធ្លាប់សិក្សាមក គេយល់បានថា ជាពាក្យប្រៀនប្រដៅនៃសាស្ដាណាមួយក្នុងលោក ដនជាសាស្ដានោះក៏មិនមានសភាពផ្សំពីសាមញ្ញសត្វប៉ុន្មានដែរ ប្លែកគ្នាចំពោះតែចំណេះវិជ្ជានឹងអធ្យាស្រ័យប៉ុណ្ណោះ ព្រោះវីរៈជននោះធ្លាប់មានការអប់រំទៅតាមគោលនៃសេចក្ដីសុខ; អ្នកសាស្ដាទាំងឡាយគេជឿបានថា ពិតជាមានមធ្យោបាយតែមួយ គឺការរំដោះខ្លួនព្រមទាំងជនជាបរិស័ទឲ្យរួចផុតចាកវដ្ដទុក្ខតែម្យ៉ាង តែអ្នកសាស្ដាទាំងនោះបញ្ចេញការរិះរករបស់ខ្លួនដែលបានសន្សំទុកមក ក៏ទៅជាមានអត្ថរសផ្សេងគ្នាទៅវិញ ការដែលមានអត្ថរសផ្សេងគ្នានេះហើយ ដែលធ្វើឲ្យអ្នកសាសនាទាំងឡាយ មានការប្រឆាំងគ្នា ដោយការរិះរក ជួនកាលបន្តទៅជាសង្គ្រាមក៏មាន សង្គ្រាមបែបនោះគេឲ្យឈ្មោះថាសង្គ្រាមសាសនា របៀបនៃសង្គ្រាមនេះ ពុំសូវមានសាយភាយទៅកាន់លោកទាំងមូលបានទេ ច្រើនមានកើតចំពោះតែវដ្ដមួយៗប៉ុណ្ណោះ ហើយជាសង្គ្រាមយ៉ាងទន់ភ្លន់ទំនងរលត់បាន ការកើតសង្គ្រាមនេះអាស្រ័យតែសេចក្ដីរំលោភនៃអ្នកសាសនាម្នាក់ៗ ដោយអ្នកនោះក្បត់គោលដើមនៃសាស្ដាខ្លួន ដែលបានប្រកាសចំពោះមធ្យោបាយរំដោះទុក្ខរបស់សត្វ ។

ដូចនោះហើយ បានជាគេបែកសាសនាទៅជាច្រើនប្រភេទ, បើតាមច្បាប់ក្នុងព្រះពុទ្ធសាសនា លោកបែកចេញជាពីរ គឺពុទ្ធសាសនានឹងពាហិរសាសនា ពាក្យពីរម៉ាត់នេះ ពួកជនក្នុងសាសនាធ្លាប់ដឹងមកស្ទើរគ្រប់រូបហើយ តែបើសិនជាមានការដឹងយ៉ាងណា

ក៏ដោយ ក៏គួរតែខំយកសាសនាទាំងពីរគឺពាហិរសាសនាមកពណ៌នាបន្តិចសិនដែរ ។

ពាហិរសាសនាបែកចេញទៅជាលទ្ធិ មានច្រើនប្រភេទ តែយើងរួមឲ្យខ្លីទៅ មានតែត្រឹមពីរយ៉ាង គឺចក្កលទ្ធិនិងសាសនលទ្ធិ

ពាក្យដែលហៅថា ចក្កលទ្ធិនេះ តើកើតពីរូបបុគ្គលណា ? នៅក្នុងរដ្ឋបែបម្តេច ? មានសភាពផ្ទុយពីអ្នកសាសនលទ្ធិយ៉ាងណាទៅ ?

សូមឆ្លើយដូចតទៅ ៖

ចក្កលទ្ធិនេះច្រើនកើតអំពីបុគ្គលដែលគ្រប់គ្រាន់ដោយវិទ្យាសាស្ត្រនិងអក្សរសាស្ត្រ ដែលមានឋានៈជាបណ្ឌិត ច្រើននៅក្នុងរដ្ឋដែលជាមហាប្រទេស ដោយប្រួមនឹងបណ្ឌិតនានាប្រទេសជាសម្ពន្ធមិត្តផងៗ

អ្នកប្រាជ្ញដែលបង្កើតលទ្ធិនេះ មិនមានសភាពផ្ទុយពីអ្នកសាសនលទ្ធិប៉ុន្មានទេ មានប្លែកចំពោះតែទឹកចិត្តប៉ុណ្ណោះ ដោយអ្នកបង្កើតចក្កលទ្ធិ ស្ថិតនៅក្នុងឋានៈជាអ្នកប្រមូលផ្តុំ ចំណែកអ្នកសាសនលទ្ធិមានដួងចិត្តជាអ្នកប្រមូលរំដោះ ។ ន័យដែលប្លែកគ្នានេះ ខ្ញុំបាទពុំបានពន្យល់ដោយពិស្តារទេ ទុកជូនលោកអ្នកវិញ្ញូជនវិនិច្ឆ័យចុះ ! ចក្កលទ្ធិនេះគេបង្កើតឡើងគ្រាន់តែរក្សាសីលធម៌របស់មនុស្សប៉ុណ្ណោះ លទ្ធិនោះ មិនមែនសម្រាប់អប់រំសីលធម៌របស់សត្វ ដើម្បីសុខទៅលោកខាងមុខឡើយ ។ ពិតមែនហើយ ថាលទ្ធិនោះមិននាំសត្វឲ្យបានសុខទៅលោកខាងមុខ តែក៏គួរចាត់ទុកថាជាលទ្ធិសម្រាប់រក្សាមនុស្សក្នុងបច្ចុប្បន្នដែរ ។ លទ្ធិសម្រាប់រក្សាសិរីរបស់មនុស្សនេះ ពុំសូវមានច្រើនបក្ខពួកទេ នៅក្នុងលោកយើងសម័យនេះមានពីរ គឺលទ្ធិប្រជាធិបតេយ្យនិងលទ្ធិរួមសម្បាច់ មហាលទ្ធិទាំងពីរនេះ កាលបើកើតឡើងហើយ តែងតែលុបបំបាត់នូវលទ្ធិតូចតាច ដែលមានកើតប្រចាំរដ្ឋមួយៗ ដោយអ្នកក្នុងរដ្ឋគេបបួលគ្នាអប់រំទៅតាមលំអាននៃលទ្ធិ ដែលខ្លួនពេញចិត្ត ក៏យកលទ្ធិនោះមកជំនួសលទ្ធិប្រចាំរដ្ឋទៅវិញ ។

អ្នកដែលបានបង្កើតលទ្ធិនេះ ក៏ទុកដូចជាបានផ្សាយ ឥទ្ធិពលខ្លួនទៅតាមបំណងដែរ ។ ម្ល៉ោះហើយការផ្សាយនៃលទ្ធិទាំងពីរនេះ ក៏កាន់តែមានអំណាចធំឡើងៗ តែងញ៉ាំងទឹកចិត្តនៃអ្នកមេលទ្ធិឲ្យអរ ដោយមិនចេញស្តី ប្រឹងតែរកមធ្យោបាយផ្សាយលទ្ធិខ្លួនឲ្យរីកទូលាយធំទៀត អ្នកផ្សាយលទ្ធិសាកលនេះ ក៏តែងបានជួបប្រទះលើផលម្យ៉ាង គឺសង្គ្រាមរវាងជាតិនិងជាតិ ព្រោះតែការខ្វែងគំនិតគ្នាដោយលទ្ធិនេះឯង ; ដូច្នោះហើយសង្គ្រាមលទ្ធិនេះមានអំណាចអានុភាពខ្លាំងខ្លា ជាងសង្គ្រាមសាសនាទៅទៀត និងនេះផ្សាយបានទូទៅក្នុងលោកទាំងមូល គេមិនអាចនឹងរម្ងាប់សង្គ្រាមបែបនោះបានដោយងាយទេ លុះត្រាណាតែបរាជ័យធ្លាក់ទៅលើលទ្ធិណាមួយហើយ ទើបសង្គ្រាមរលត់ លទ្ធិដែលមានជំនះក៏ត្រូវទទួលទឹកមុខដ៏រីកថ្លា ដើរលេងពេញពិភពលោកដោយ

គ្មានកោតញញើតឡើយ ។

ចុះចំណែកសាសនលទ្ធិវិញ តើមានទំនងបែបណាទៅ ?

សាសនលទ្ធិនេះមានន័យផ្សេងដោយឡែកទៅទៀត ជាលទ្ធិសម្រាប់តាំងខ្លួនធ្វើជាព្រះលើប្រជាករ ដោយបានសាងស្ពានមួយគឺធម្មរស សម្រាប់ឲ្យសត្វដើរទៅកាន់លោកខាងមុខ លទ្ធិនេះតែងមានជាប់ជានិច្ចចំពោះរដ្ឋមួយ ១ ព្រោះជាសរណៈផ្ទាល់ខ្លួនសម្រាប់មនុស្សក្នុងលោក ។ គេតែងអួតសរសើរថាមានតែសាសនាគេនេះទេ ដែលអាចយោងមនុស្សឲ្យទៅកើតស្ថានសួគ៌បាន នេះចំពោះលទ្ធិសាសនាដែលនៅជាមួយនឹងលទ្ធិប្រជាធិបតេយ្យ ។ ចំណែកលទ្ធិសាសនាដែលនៅជាមួយនឹងលទ្ធិរួមសម្បត្តិវិញ មានការផ្ទុយគ្នាស្រឡះ ហើយពិបាកនឹងរកសាសនាមកបង្ហាញឲ្យយល់ផង ព្រោះច្បាប់នៃលទ្ធិនេះហាមមនុស្សមិនឲ្យមានសរណៈក្រៅពីច្បាប់ប្រចាំរដ្ឋ គ្មានមនុស្សទំនេរ គ្មានទីដីដែលរួចពាកពន្ធ បើដូចនេះតើយើងនឹងអាចវិនិច្ឆ័យថា មានសាសនានៅជាមួយនឹងលទ្ធិនោះដែរឬទេ ? ព្រោះបព្វជិតក្នុងសាសនាសុទ្ធតែជាមនុស្សទំនេររួចពាកពន្ធ នឹងត្រូវទទួលការគោរពរាប់អានចិញ្ចឹមរក្សាពីបរិស័ទអ្នកប្រតិបត្តិតាមៗ ម៉្លោះហើយឃើញថាលទ្ធិសាសនានៅជាមួយនឹងលទ្ធិរួមសម្បត្តិមិនបាន ; បើតាមសេចក្ដីប្រកាសដែលគេធ្លាប់ដឹងមកថា លទ្ធិនេះយករដ្ឋាភិបាលធ្វើជាសាសនា ; ហេតុដូចម្ដេចបានជាយករដ្ឋាភិបាលធ្វើជាសាសនា? ព្រោះយើងបានដឹងមកហើយថា កាលបើមានភ័យយើងត្រូវទីពឹងលើវត្ថុសក្ដិសិទ្ធិ ចុះបើយើងទីពឹងសេចក្ដីសុខ ពីរដ្ឋាភិបាលហើយយើងចាំបាច់ទៅរកអ្នកដទៃធ្វើអ្វីទៀត ! ហេតុដូចពោលមកនេះ សរឲ្យឃើញថា លទ្ធិរួមសម្បត្តិនឹងប្រាសចាកសាសនាមែន ។

សេចក្ដីដែលបានរៀបរាប់ទាំងប៉ុន្មាន គ្រាន់ជាការបំភ្លឺឲ្យយល់តែពាក្យថាលទ្ធិនឹងសាសនា ដែលតែងតែមានន័យផ្សេងគ្នាជាដរាប បើគេយកសេចក្ដីទាំងនោះប្រមូលបញ្ចូលគ្នាទៅ ក៏ចូលនៅក្នុងផ្ទៃនៃសាសនាទាំងអស់ ដោយហេតុនោះហើយបានជាយើងសួរពោលពីសាសនានោះម្ដងទៀត ។

ខ្ញុំបានបញ្ជាក់មកហើយ ថាលទ្ធិសាសនាចែកចេញជាពីរប្រភេទគឺ ពុទ្ធសាសនា នឹងពាហិរសាសនា ចំណែកពាហិរសាសនានោះ ខ្ញុំបានពណ៌នាខ្លះមកហើយពីខាងដើម ជាសាសនានៃគ្រូណាមួយដែលប្រដៅសត្វដោយន័យផ្សេងពាកពុទ្ធសាសនាដូចយ៉ាងសាសនាព្រាហ្មណ៍ មហាម័ត យេស៊ូជាដើម សាសនាទាំងនោះខ្ញុំមិនអាចលាតត្រដាងនូវសេចក្ដីប្រៀនប្រដៅរបស់គេក្នុងទីនេះបានទេ ដោយទុកាសវិពេក តែសូមយកន័យបែកខាងពុទ្ធសាសនាមកពណ៌នាយ៉ាងខ្លីទុកជាសណ្ដាប់តទៅ ៖

ព្រះពុទ្ធសាសនាក៏ជាលទ្ធិមួយក្នុងលោកនេះដែរ

ដើមកំណើតនៃសាសនានេះ កើតនៅប្រទេសឥណ្ឌា អ្នកប្រាជ្ញខាងពុទ្ធសាសនាបានរកឃើញទីចាប់កំណើតនៃសាសនានេះប្រាកដ ប្រវត្តិសាស្ត្រមហាបុរសនៃសាសនានេះ ក៏មានការពិតប្រាកដដល់សម័យនេះដែរ គេរកឃើញនៅប្រទេសណេប៉ាល់; គ្រូដើមនៃសាសនានេះ មាននាមថាសិទ្ធត្ថ ជាព្រះរាជបុត្រព្រះបាទសិរីសុទ្ធោទន និងព្រះនាងសិរីមហាមាយា, ទ្រង់ជាបុគ្គលអស្ចារ្យតាំងពីព្រះរាជកុមារមកដល់ពេលក្រោយទ្រង់បានបំពេញបារមីធម៌ ដើម្បីព្រះពុទ្ធអស់រយៈកាល៦វស្សា ទីបំផុតទ្រង់បានផ្ចាញ់មារទេវបុត្រទាំងសេនទាំងលាន ដោយមិនបានប្រើអាវុធគល់ឡើយ ការឈ្នះនេះជាជំនះដ៏វិសេសដែលអ្នកប្រាជ្ញបានចារិកទុកក្នុងប្រវត្តិសាស្ត្រនៃពុទ្ធសាសនា ។

ចាប់តាំងពីទ្រង់មិនទាន់បានឡើងឋានៈជាព្រះពុទ្ធ មកដល់បានឋានៈជាព្រះពិតប្រាកដហើយ គេពុំដែលឃើញព្រះអង្គមាន ការបៀតបៀនដល់សត្វណាមួយឡើយ ព្រះអង្គតែងមានព្រះទ័យតាំងនៅក្នុងព្រហ្មវិហារធម៌ ៤ គឺមេត្តា ករុណា មុទិតា ឧបេក្ខា ហើយទ្រង់បានប្រដៅបរិសទ្យរបស់ទ្រង់ឲ្យប្រាសចាកការរាឃាតព្យាបាទចងគំនុំ ហើយត្រូវតែបូជាតាមទ្វារទាំងបី ដើម្បីសន្តិធម៌ គឺព្រះនិព្វាន ទ្រង់ឲ្យអ្នកពុទ្ធសាសនាចេះប្រើមេត្តាធម៌តាមព្រះអង្គ ការដែលរៀនធ្វើមេត្តាធម៌ជាដំបូងគេត្រូវយល់ថា សត្វក្នុងលោកទាំងមូលសុទ្ធតែធ្លាប់មានកំណើតជាបងប្អូនរួមឈាមតែមួយ សូម្បីជាតិតិរច្ឆានក៏ធ្លាប់កើតរួមឈាមជាមួយនឹងយើងដែរ មុននឹងយើងពិឃាតៈបៀតបៀនដល់សត្វជំពូកនេះក៏គួរតែយើងហាមប្រហារប្អូនប្រុស-ស្រីរបស់យើងផង ជនដែលមានគំនិត គ្រាន់តែស្រាបទៅតាមយោបល់ត្រឹមប៉ុណ្ណោះក៏អាចរកសុខឲ្យជួបគ្នាបានដោយងាយ យើងមិនចាំបាច់យកបរមត្ថធម៌នៃសាសនានេះ មករៀបរាប់ឲ្យវែងឆ្ងាយទេ យើងគ្រាន់តែពិចារណាទៅតាមគោលដំរូនេះមើល! តើនឹងបានផលដូចម្ដេច? បើបត្វមានមេត្តាទៅកាន់គ្នាហើយ តើការឈ្លោះប្រកែកដោយរឿងនឹងមានពីណា? បើយើងលះបង់ទោសមូលបីហ្នឹងគឺ គឺការលោភចង់បានហួសហេតុ ការក្រោធខឹងឥតគ្រាប្រណី ការវង្វេងប្រាសចាកផ្លូវខុសត្រូវ ធម៌ដ៏លាមកទាំងបីនេះយើងលះបង់ហើយ តើនឹងអាចដេកក្រាំក្នុងសេចក្តីសុខបានឬទេ? ។

យើងយល់ថា សាសនាព្រះពុទ្ធជាម្ចាស់អាមស-មណគោតមពិតជាធ្វើសត្វក្នុងលោក ឲ្យឈប់ឈ្លោះប្រកាន់គ្នាតទៅថ្ងៃមុខ ឲ្យបានឋិតនៅក្នុងសីលធម៌ ឲ្យមនុស្សថ្លៃថ្នូរទៅតាមការពិតត្រង់ ជាអ្នកដើរតាមផ្លូវកណ្ដាលគឺសន្តិធម៌ សត្វលោកនឹងប្រាសចាកទុក្ខ ជួបប្រទះនឹងសេចក្តីសុខតទៅអនាគតជាប្រាកដ ទីបំផុតនឹងដល់ស្ថានមួយទៀត ដែលទុក្ខគ្រប់យ៉ាងតាមមិនទាន់គឺព្រះនិព្វាន ។

ដូច្នេះហើយបានជាយើង ពុទ្ធបរិសទ្យ មានសទ្ធាក្នុងពុទ្ធសាសនាប្រមូលគ្នាជាក្រុមបង្កើតបានជា

សមាគមមួយ ហៅថាសមាគមមិត្តសាលាបាលី ដើម្បីអប់រំព្រះពុទ្ធសាសនាសម្រាប់មាតុភូមិយើង និងរក្សាសាមគ្គីធម៌រវាងប្រជាជាតិក្នុងលោក ឲ្យរួចចាកការបៀតបៀនដោយចងអាឃាត គំនុំគ្នា ។

នៅទីបញ្ចប់នេះខ្ញុំសូមអំពាវនាវដល់ជនរួមជាតិ ដែលស្រឡាញ់សេចក្ដីសុខ ដោយប្រាសចាកការបៀតបៀន ចូលមករួមជាមួយនឹងសមាគមយើង ប្រយោជន៍នឹងជួយជំហពុទ្ធសាសនា ឲ្យមានវឌ្ឍនាការប្រព្រឹត្តបានទូទៅក្នុងលោក ។

ជយោ ! ពុទ្ធសាសនា

ហួត-ហៀម

---

# គួរឈប់ប្រកាន់វណ្ណៈ



ដោយហេតុប្រទេសខ្មែរយើង នៅមានមនុស្សប្រកាន់ខ្លួនហួសប្រមាណ ហើយមានមនុស្សរាប់អានតែអ្នកមានទ្រព្យ និងអ្នកមានយសសក្ដិ ព្រមទាំងមានខ្លះប្រកាន់មានះថាខ្លួនជាពូជខ្ពស់ ត្រកូលខ្ពស់ រហូតដល់ទៅភ្លេចខ្លួន ថាខ្លួនជាជាតិខ្មែរ ឬខ្លួនត្រូវមានសមភាពដូចជនដទៃដែរនោះ យើងយល់ថា គួរឃោសនា ឬគួរមានបទបញ្ញត្តិ អំពីសមភាពឲ្យកើតក្នុងប្រទេសយើងតទៅ ព្រោះប្រទេសយើង បានឯករាជ្យបរិបូណ៌ហើយ គួរតែធ្វើជាតិយើងឲ្យមានសមភាពឡើង ។

យើងសូមបញ្ជាក់ថា ច្បាប់ស្មើភាព (សមភាព) នេះ ពុំមែនយើងទើបនឹងផ្ដើមនិយាយអន្ទងចិត្តជនរួមជាតិឲ្យកាន់យកដោយឥតហេតុផលទេ គឺច្បាប់នេះមានមកយូរហើយ តែយើងបំភ្លេចចោលអស់ទៅ ។

សមភាពនេះ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូយើង ដែលព្រះអង្គមានញាណបរិសុទ្ធ ទ្រង់យល់អតីតអនាគតបច្ចុប្បន្នលើសទេវតានិងមនុស្ស ទ្រង់បានបញ្ញត្តិឲ្យពុទ្ធបរិសទ្យប្រព្រឹត្តតាម ដូចមានសំដែងក្នុងគម្ពីរបិដកថា ជនទាំងឡាយទោះបីពូជព្រាហ្មណ៍ក្ដី ខត្តិយៈក្ដី វេស្សៈក្ដី សុទ្រៈក្ដី ចណ្ឌាលក្ដី អ្នកបោសថ្នល់ក្ដី អ្នកកើបសំរាមក្ដី តែបួសមកបួសជាភិក្ខុ ប្រព្រឹត្តធម៌និងវិន័យ របស់តថាគតហើយ ឈ្មោះថាសមណៈ(អ្នកស្ងប់), ឈ្មោះថាសក្យបុត្ត(កូនព្រះសក្យមុនី)ទាំងអស់ ។

ជាតិខ្មែរយើងជាជាតិកាន់ព្រះពុទ្ធសាសនា គួរតែមានចិត្តរាប់អានព្រះពុទ្ធស្មើដោយជីវិត គឺគោរពព្រះពុទ្ធ កាន់តាមព្រះពុទ្ធដីកានេះឲ្យម៉ឺងម៉ាត់គ្រប់គ្នា មិនត្រូវនាំគ្នាបែងជាវណ្ណៈ ដល់ទៅសេពគប់គ្នាមិន

បាននោះទេ ។ មានខ្លះពួកអ្នកស្រែចំការដូចគ្នា តែកាលណាបានឋានសក្តិខ្ពស់ ឬបានធ្វើនាម៉ឺនបន្តិចបន្តួច ឡើងត្រឡប់ជាខ្ពើមអ្នកស្រែចំការគ្នាឯងពីដើមអស់ ធ្វើកែក្រអឺតក្រទមដាក់គ្នា រកតែគ្នាប្រស្រ័យផងពុំបាន ។

ការប្រកាន់ខ្លួន ពុំមែនជាធម៌ប្រសើរឡើយ គឺជាធម៌មួយនាំឲ្យវិនាសកាំងស្រុង នាំឲ្យបែកសាមគ្គីជាតិ ព្រោះពួកអ្នកប្រកាន់ខ្លួនច្រើនតែយល់ថា "អញដោយអញឯងដោយឯង" ម្ល៉ោះហើយ ច្រើនសំដែងអាកប្បកិរិយារឹងរូបរៀងខ្លួនៗ កិច្ចការណាក៏ដោយ តែមានការប្រកែកប្រកាន់គឺមានអស្មិមានះហើយ ការនោះគ្មានបានជាប្រយោជន៍ឡើយ ឧបមាដូចអ្នកធំម្នាក់ ប្រើអ្នកតូចជាងខ្លួន ជានាម៉ឺនក្តីជាពស្ត្រប្រជាក្តីដែលស្គាល់ច្បាប់សមភាពឲ្យធ្វើការអ្វីមួយ, បើអ្នកតូចជាងនោះយល់ថាអ្នកធំនោះមិនប្រកាន់ខ្លួន គឺជាមនុស្សមិនសំគាល់គេដូចជាសត្វតិរច្ឆាន ហើយការដែលធ្វើតាមបង្គាប់នឹងធ្វើទៅដោយស្ម័គ្រអស់ពីពោះ; បើកាលណាឃើញថាអ្នកធំនោះប្រកាន់រើសវិញ មុខជាអ្នកតូចនោះធ្វើទៅដោយមិនពេញចិត្តជាប្រាកដ ។ អ្នកតូចអាចធ្វើតាមដែរ តែការដែលធ្វើនោះមុខជាធ្វើដោយគ្រដរប្តធ្វើដោយសារតែខ្លាចអំណាចប៉ុណ្ណោះ ឯចំណែកការងារវិញពុំបានជាត្រឹមត្រូវល្អឡើយ ។

យើងសង្កេតឃើញមានសង្គមខ្លះ កាន់អស្មិមានះជាបំផុត ហាក់ដូចពួកគេនោះជាទេវតាទាំងអស់; សង្គមនោះលុះតរមក បេះតែអាប់រស្មីទៅបន្តិចម្តងៗ សឹងតែរកនរណាអើតអើតគកផងពុំបាន ។ ការប្រកាន់ខ្លួននេះចាត់ជាធម៌មួយអាក្រក់បំផុត, មនុស្សដែលមានការប្រកាន់ខ្លួន យូរៗទៅច្រើនតែក្លាយទៅជាមនុស្សឈ្លើយខុសពីគេ ។

គួរឲ្យឆ្ងល់ដែរចំពោះការប្រកាន់ខ្លួននេះ នឹងបានផលយ៉ាងណាខ្លះ ?

កាលពីដើមដែលប្រទេសយើងនៅជាប្រទេសអាណានិគមរបស់ជនបរទេស, កាលណោះគួរណាស់តែយើងនាំគ្នាចងបាច់ដោយមេត្តាចិត្ត ព្រោះជាជាតិដូចគ្នា ហើយនៅក្រោមអាណាព្យាបាលគេក៏ដូចគ្នា តែហេតុដែលកន្លងទៅហើយមិនដូច្នោះទេ គឺមនុស្សដែលមានការប្រកាន់ជាប់នឹងខ្លួនព្រោះតែឋានៈរបស់ខ្លួន អ្នកទាំងនោះត្រឡប់ជាធ្វើបាបគ្នាឯងទៅវិញ ។

ម្ល៉ោះហើយការធ្លាប់ខ្លាចជនបរទេសមធ្យមផល់មកគ្នាឯងយើងត្រូវខ្លាចឡើងជាទ្វេគុណ ។

ប្រទេសខ្មែរយើងសព្វថ្ងៃបានឯករាជ្យស្មើមុខនឹងប្រទេសនានាក្នុងលោកហើយ ដូច្នេះ យើងគួរលះបង់ចោលអស្មិមានះនោះឲ្យអស់ទៅ ដើម្បីរួបរួមគ្នាកសាងជាតិឲ្យចំរើនរួសរាន់ទាន់សម័យនឹងគេ ។

ជាតិគេដទៃដែលមានសភាពរស់នៅដូចយើងដែរ មានជាតិឥណ្ឌៀជាដើម សព្វថ្ងៃគេកំពុងតែប្រឹងប្រែងខ្លាំងណាស់ ដើម្បីកំចាត់អស្មិមានះនេះ ។ ជាតិឥណ្ឌៀពីដើមគេជាមេប្រកាន់អស្មិមានះមួយយ៉ាង

រឹងក្នុងអាស៊ីទ្វីប តែឥឡូវនេះគេដឹងខ្លួនគេ ហើយគេតាំងចាប់កំចាត់ធម៌អាក្រក់នេះចេញភ្លាម ដោយតាំងបទបញ្ញត្តិមួយក្នុងរដ្ឋធម្មនុញ្ញហាមកុំឲ្យមនុស្សប្រកាន់វណ្ណៈថ្នាក់ជាន់តទៅទៀត ។ សូម្បីគេធ្វើទៅពុំទាន់បានផលល្អ តែឃើញថាមានវឌ្ឍន៍ធំទូលាយណាស់ហើយ ដូចជាលោកវិនោភាភាវេ បានព្យាយាមសព្វថ្ងៃនេះជាដើម ។

យើងសូមនាំរឿងលោកវិនោភាភាវេមកផ្សាយបន្តិច ដើម្បីជាបដិទស្សន៍របស់បណ្ឌិត ។

លោកនេះជាសិស្សសំណប់របស់មហាត្មៈគន្ធី ។ សព្វថ្ងៃ អ្នកស្រុកនៅប្រទេសឥណ្ឌា គេហៅថា "លោកគ្រូធំ ខាងចំណាយបោលទូប្រវត្តិសាស្ត្រ" ។ លោកវិនោភាភាវេនេះ ជាមេគម្រប់គម្រានៃលទ្ធិមហា-ត្មា ជាបុគ្គលមានកំណើតក្នុងត្រកូលព្រាហ្មណ៍ដែលអ្នកប្រទេសធ្លាប់ប្រកាន់ថាជាត្រកូលខ្ពស់ជាងត្រកូលចណ្ឌាល តែលោកគ្រូឡប់ជាមានចិត្តស្រឡាញ់រាប់អាននឹងយកចិត្តទុកដាក់ចំពោះពួកចណ្ឌាលទៅវិញ ។

សេចក្តីពិតប្រទេសឥណ្ឌា ប្រកាន់មាំថា ពួកចណ្ឌាលនេះ, តែអ្នកមានត្រកូលខ្ពស់ទៅសេពគប់ហើយនឹងក្លាយទៅជាមនុស្សស៊ីយ សៅហ្មងមួយជីវិត ។ ចំណែកលោកវិនោភាភាវេលោកហៅពួកចណ្ឌាលថាត្រកូលហរិជ័ន (កូនព្រះអ.ទិទេព) ។

គ្រប់ពេលវេលាដែលលោកដើរចារិកទៅតាមជនបទតូចធំក្នុងប្រទេសឥណ្ឌា ដើម្បីសុំដីពីអ្នកមានធំ ៗ មកចែកចាយដល់អ្នកក្រឲ្យមានកន្លែងរកស៊ីធ្វើការនោះ លោកភាវេដែលប្រជាជនទូទៅគោរពរាប់អានពេញស្រុកពេញនគរតែងតែចូលទៅធ្វើកិច្ចសន្ទ-នាជាមួយនឹងពួកចណ្ឌាល ដែលនៅក្នុងកន្លែងដ៏សែនវេទនា ដែលពុំដែលមាននរណាហានដើរចូលទៅម្តងសោះ ។ រហូតដល់ទៅអាហាររបស់ពួកនេះ លោកក៏ទទួលមកពិសាដោយពុំមានសេចក្តីរង្កៀសបន្តិចបន្តួចឡើយ ។

យើងសូមរំលឹកថា នោះបើរដ្ឋធម្មនុញ្ញឥណ្ឌាដែលធ្វើឡើងតាំងពីទទួលឯករាជ្យពីអង់គ្លេស កាលគ.ស. ១៩៤៩ មានបញ្ញត្តិកុំឲ្យទទឹងទាស់ដល់សិទ្ធិនៃពួកចណ្ឌាលក៏ដោយ, តែក្នុងផ្លូវប្រតិបត្តិ ពួកចណ្ឌាលក៏នៅតែជាបុគ្គល ដែលគេសង្កត់សង្កិនជានិច្ចកាលដូចពីដើម ។ លោកភាវេ យល់ច្បាស់ដូចលោកគន្ធីថា "សេចក្តីយុត្តិធម៌ដ៏ពិតប្រាកដសំ-រាប់ពួកចណ្ឌាលនោះ ពុំអាចបានមកអំពីបញ្ញត្តិដែលចេញដោយមនុស្សសរសេរទេ បើនឹងបានក៏ត្រូវបានដោយចិត្តថ្មើមដ៏ពិតប្រាកដរបស់មនុស្សឯណោះ" ។

មានដំណាលថា កាលពីខែកញ្ញា ១៩៥៣ ដែលទើបនឹងកន្លងទៅនេះ លោកវិនោភាភាវេ បានត្រេចទៅកាន់ស្រុកពិហារ ដែលអ្នកស្រុករាប់អានថាជាកន្លែងសក្តិសិទ្ធក្នុងខេត្តពិហារ ។ តំបន់នេះពួកអ្នកបួស ដែលព្រះហើនក្នុងសេចក្តីសក្តិសិទ្ធរបស់

ខ្លួនបុរះប្រកាន់យ៉ាំគន្លងប្រពៃណី ក៏ឯកពួកបណ្ឌិតណាលជានិច្ច ស្ដីបន្ទោសថា ច្បាប់គាត់ខុសហេតុហើយក៏ដោយ ។

លោកវិនោភាភាវេ លុះបានដឹងដូច្នោះ លោកនឹកប្រាប់មួយរំពេច ម៉្លោះហើយនៅវេលាសូត្រមន្តក្នុងឱកាសមួយនោះ លោកបានចូលទៅកាន់វិហាររបស់អ្នកបួសតាំងនោះហើយលោកបានពោលថា "ព្រះវិហារតេយ៍នាថនេះ មានអាយុជាង ១.២០០ ឆ្នាំហើយក្នុងស្រុកពិហារនោះ ដូច្នេះចំពោះបញ្ហាដែលទាក់ទងនឹងការសូត្រមន្ត ដើម្បីទុកថ្វាយព្រះអាទិទេព មិនគួរនឹងហាមឃាត់មួយ ជាគ្រឿងរាំងរកដល់មនុស្សផ្សេងវណ្ណៈទេ ។

ក្នុងពេលល្ងាចនោះឯងខណៈដែលយប់សន្ធ្យាកំពុងតែគ្របដណ្ដប់ជិតផ្ទៃនៃព្រះវិហារ ដ៏សក្ដិសិទ្ធលោកវិនោភាភាវេ ក៏ប្រើសម្ដីរបស់លោក ដើម្បីល្បងមើលទឹកចិត្តមនុស្សលោកក្លាម ៗ លោកឈានដើរដើរយ៉ាងសន្សឹម ៗ នៅក្នុងព្រះវិហារជាមួយសិស្សានុសិស្សដែលមានច្រើននាក់ជាពួកបណ្ឌាល ៗ កាលបើចូលទៅដល់ខាងក្នុងហើយ ពួកអ្នកបួសដែលព្រហ្មណ៍ព្រោះកាន់វណ្ណៈ ប្រហែល៥០រូបបានកន្ត្រាក់ដំបងព្រនង់វែង ចូលរុកកានក្បួនជូនលោកវិនោភា-ភាវេ ដោយពុំនិយាយដូចម្ដេចសោះ ។ លោកវិនោភាវេ កាលបើប្រទះនឹងហេតុការណ៍យ៉ាងស្រួមតាមគោលអហិង្សាដូច្នោះ លោកក៏ចេញបញ្ជាឲ្យសិស្សានុសិស្សតាំងឡាយអត្ដុយចុះក្លាម ហើយស្រែកថា "ចូរបណ្ដោយឲ្យគេវាយយើងចុះ កុំតនឹងគេឡើយ ក្នុងខណៈនោះខ្លួនលោកនិងសិស្សានុសិស្សតាំងឡាយ ក៏អត្ដុយស្ងប់ស្ងៀមបណ្ដោយឲ្យអ្នកបួសដែលលុះក្នុងក្រោធទោសៈ សំពងយ៉ាងមិនប្រណីដោយមិនដកដៃ ប៉ុន្តែក្នុងឱកាសជាមួយគ្នានេះសិស្សរបស់លោកម្នាក់គយក្រែងលោកនឹងស្លាប់ ទើបស្ទុះទៅពាំងខ្លួនលោក ៗ ស្ទើរដូច្នោះ, លោកក៏នៅតែមិនដុតពីបានរបួសធុកជាទីវេណីកឡើយ ៗ ឯសិស្សម្នាក់ត្រូវព្រនង់សន្ធប់នៅកន្ទុង, ហើយមាន ៣ នាក់ទៀតរបួសធ្ងន់ផាបដល់ដឹកទៅផ្ទះពេទ្យ ក្រៅពីនោះមានរបួសបន្តិចបន្តួច ដើម្បីទុកជាទីរាកដល់ខណៈពាន់ម្នាក់បន្តិច ៗ គ្រប់ ៗ គ្នា ។

កាលបើនាំសង្ខារដំច្រេមច្រេម ត្រឡប់មកដល់ខ្ទមសំណាក់ហើយ លោកវិនោភាភាវេ បានឲ្យទុកទោសដល់សិស្សានុសិស្សមួយរំពេច, លោកមិនឲ្យបង់គំនុំមួយឈើចិត្ត ឈើថ្លើមនឹងបញ្ជិតកំណាចទាំងនោះ មានសារៈសំខាន់ក្នុងទុកទោសរបស់លោកមួយកន្លែងថា "យើងកុំព្យាបាទនឹងមនុស្សដែលព្យាបាទយើងព្រោះមនុស្សដែលព្យាបាទគេ គ្មានល្អខ្ពង់ណាស់ ។ គ្នាពុំយល់ថាការព្យាបាទគេជាអំពើអាក្រក់ឡើយ" ។

ស្ដីរំលឹកទៀតថា ដំណឹងប្រទូសរ៉ាយរូបកាយលោកគវេនេះមិនបាត់ស្ងាត់ទេ ផ្សាយទៅពាសពេញគ្រប់ទិសានុទិសហើយក្នុងខណៈជាមួយគ្នានោះ សំ-ឡេងប្រឆាំងនឹងអំពើយង់ឃ្នង់នៃអ្នកបួសតាំងនោះ ក៏

ចេះតែមានខ្លាំងឡើងៗ អំពីទីផ្សេងៗ ។ ដោយចំពោះ លោកយោវហាល់នេរូ នាយករដ្ឋមន្ត្រីឥណ្ឌាបាន ប្រលោមពួកអ្នកបួសយ៉ាងខ្លាំងក្លា ។ លោកនេរូ មានប្រសាសន៍មួយឃ្លាថា "ការប្រទូសរ៉ាយរូបកាយគេយ៉ាងទារុណដូច្នេះ សរឲ្យឃើញថា អ្នកបួសទាំងនេះធ្វើសីលធម៌ឲ្យទ្រុឌទ្រោមខ្លាំងណាស់ មិនសមជាអ្នកបួសដែលប្រកាសខ្លួនជាអ្នកបំរើសាសនា ហើយយកសាសនាមកញុំាញីនឹងបាតាដែលប្រឡាក់ដោយកំញុ៉មទោសៈដូច្នេះឡើយ ; អ្នកបួសទាំងនេះអួតអាត្មាថាជាអ្នកបរិសុទ្ធ តែសេចក្ដីពិត គឺអាស្រ័យសាសនាជាគ្រឿងទាក់លាភទាំងស្រុង" ។ ចំណែកលោកប្រធានាធិបតីកដេន្ទ្រប្រាសាទ ដែលទទួលទឹកដីដ៏ធំមហិមារបស់លោកក្នុងស្រុកពិហារ ចំពោះលោកវិនោភាភាវេ ដើម្បីឲ្យយកទៅចែកដល់អ្នកស្រែដែលគ្មានទីដីជាកម្មសិទ្ធរបស់ខ្លួននោះ, លោកបានបញ្ជូនសារមួយសំដែងសេចក្ដីស្ដុតរន្ធត់ចិត្ត ទៅកាន់គណៈលោកវិនោភាភាវេ នៅពេលដែលលោកបានជ្រាបដំណឹងនោះភ្លាម ។ ឯគណៈបក្សសង្គមនិយមដែលជាបក្សជំទាស់ របស់រដ្ឋាភិបាលនេរូ បានប្រទូស្តរដ្ឋាភិបាលនេរូថា "មិនគិតពាក់ការឃុំគ្រងដល់បុគ្គល ដែលប្រជាជាតិឥណ្ឌាច្រើនលាននាក់ រាប់អានថាជាមនុស្សវិសេស" ។

គេបានដឹងថា ដោយមិនឲ្យលោកខ្លួនទៅយឺតយូរឡើយ ក្រុមប៉ូលិសនៅស្រុកពិហារបានចាប់បព្វជិត ១២ រូបភ្លាម ក្នុងឋានៈជាអ្នកប្រទូសរ៉ាយរាងកាយលោកភាវេ នឹងបក្សពួកលោកព្រមទាំងចោទប្រកាន់ថា ធ្វើការរាំងរាមិនឲ្យពួកបណ្ដាលចូលទៅធ្វើបុណ្យក្នុងវត្តជាការទទឹងទាស់នឹងបទបញ្ញត្តិ ក្នុងរដ្ឋធម្មនុញ្ញផង ។

នេះជាការៈដំបូងក្នុងប្រវត្តិសាស្រ្តដែលពួកបព្វជិតធ្លាក់ខ្លួនទៅជាចំឡើយនៃក្រុមអយ្យការចោទ, សូម្បីការសង្កត់សង្កិននូវសិទ្ធិពួកបណ្ដាលបាន មានមនុស្សចូលចិត្តប្រព្រឹត្តនៅឡើយ ។

---

## សភាពនៃសត្វ

### ស្វាផុះអាចម៍ដាក់ក្បាលអ្នកមានគុណ

ទុកនិបាតជាតក

---

ក្នុងព្រៃធំនៃដែនពារាណសី ជាទីអាស្រ័យនៅនៃពួកសត្វទាំងឡាយ មានស្វាច្រើនជាងសត្វដទៃ កណ្ដាលព្រៃមានអណ្ដូងទឹកមួយហ៊ោងជ្រៅ ពួកសត្វចុះផឹកទឹកមិនបាន តែនៅជិតផ្លូវពួកមនុស្សដែលសញ្ចរទៅមកបានយោងទឹកដោយវៀវែងឡើងមកចាក់ទុកនឹងត្រឡោកឲ្យហ្វូងសត្វផឹកយកបុណ្យ ។ គ្រាមួយ គ្មានមនុស្សសញ្ចរទៅមកពីរបីថ្ងៃ ហ្វូងសត្វព្រៃអត់ទឹក ។ មានសត្វស្វាមួយស្រេកខ្លាំងណាស់ ក៏លោតចុះឡើងក្បែរអណ្ដូងទឹកជួនជាពេលនោះមានបុរសម្នាក់មានធុរៈត្រូវដើរមកតាមផ្លូវ នោះក៏

យោងទឹកមកផឹកទឹកលាងជើងដៃ លុះឃើញស្វានោះ សំដែងអាការដូច្នោះក៏ដឹងថា ស្វាស្រេកទឹកគាត់ក៏ទឹក អាណិត ហើយយោងទឹកមកដាក់ត្រង់ត្រឡុកដូច្នោះ ទុកឲ្យវាផឹក រួចហើយគាត់ក៏ទៅអង្គុយសម្រាកកាយ ក្រោមម្លប់ឈើមួយដើមក្បែរទីនោះ ស្វានោះក៏ស្ទុះ ទៅផឹក ៗ ទាល់តែឆ្អែតលុះមានកំឡាំងកំហែងស្រួលបួលហើយ ក៏ចូលទៅអង្គុយជិតបុរសនោះញាក់មុខ មាត់ពព្រិតហើយបញ្ចេញសម្លេងខេះៗ ។

បុរសនោះឃើញកាតវេទគុណរបស់ដូច្នោះ ក៏ស្រែកថា “អញឲ្យទឹកហ៊ានច្រើនដល់ឯងដែលឯង កំពុងក្រោះហើយស្រេកហ៊ានខ្លាំង ដល់ឯងផឹករួច ហើយមកញាក់មុខមាត់ដាក់អញ ហើយសង្គ្រុកអញ ទៀត ការសង្គមនឹងមនុស្សអាក្រក់មិនល្អទេរឺ”

ស្វាតបថា “ឯងសំគាល់ថាអញធ្វើព្រមបុណ្ណោះ នេះអស់រឿងហើយឬ? ទៅទៀត ចាំអញជុះអាចម៍ ដាក់ក្បាលឯងសិន ទើបឯងទៅបាន ។ រួចហើយក៏ និយាយដល់សភាពពួកវាថា “ឯងដែលដឹង-យល់-ឮ នឹងឃើញដែរឬ ស្វាណាខ្លះដែលប្រាកដថាមានស៊ីល នេះនែអញនឹងជុះអាចម៍ដាក់ក្បាលឯង ព្រោះសភាព នេះជាទំនៀមរបស់ពួកអញ” ។

អធិប្បាយរបស់ព្រះអដ្ឋកថាចារ្យថា“ អម្ហាកំ ហិ មក្កដានំ នាម ឯសា ធម្មតា អយំ ជាតិបកាសោ យទិទំ ឧបការកស្ស សីសេ វច្ចំ កាតព្វំ ការដែល ត្រូវតែជុះអាចម៍ដាក់ក្បាលអ្នកឧបការៈឲ្យបាន នុះជា ធម្មតា ជាសភាពប្រចាំកំណើតរបស់ពួកអញគឺពួក សត្វដែលមានឈ្មោះថា ស្វា”

រឿងនេះសំដែងឲ្យឃើញថា “សូម្បីជាមនុស្ស តែនេះគុណក៏អាចពោលបានថា ក្នុងពង់កាយមនុស្ស នោះ មរនជាតិនឹងសភាពស្វាសណ្ឋិតនៅ ហើយ បើបានជួបនឹងមនុស្សដូច្នោះ ក៏ត្រូវតែបញ្ចេញមុខពាន ឲ្យញឹកៗថា” “ន សង្គមោ បាបជនេន សេយ្យោ សង្គមនឹងមនុស្សអាក្រក់មិនល្អទេ”

ស្ងួន-សុរិទ្ធ

---

# នរកនៅឯណា?

តពីលេខ ១០ មក

ការដែលនឹងមើលឃើញនរក ខ្លះទង់ដែង ដើមរកាដែក ឃើញយមបាលដេញដោលសួរបាបកម្មអ្នក ដែលស្លាប់ទៅហើយ លោកសំដែងថាទាល់តែបាន ភ្នែកទិព្វ អ្នកដែលមិនបានភ្នែកទិព្វរមែងមើលមិន ឃើញនេះជាពុទ្ធដីការបស់ព្រះពុទ្ធឃោសាចារ្យ ។ តែខ្ញុំបានឃើញសេចក្ដីក្នុងគម្ពីរមួយកន្លែង ដែលជា ពុទ្ធដីការបស់ព្រះសម្ពុទ្ធសុទ្ធៗ ក្នុងសេចក្ដីនោះធ្វើឲ្យ ខ្ញុំចូលចិត្តថា សូម្បីមនុស្សដែលមិនបានភ្នែកទិព្វក៏ អាចមើលនរកឃើញដែរ ឲ្យតែមានសេចក្ដីបេះដឹង ខ្ពស់ជ្រៅជ្រះ ។ បញ្ហានៃនរកនេះនឹងមានចំពោះពួក



មនុស្សដែលនៅមិនទាន់ចួបប្រទះនឹងលោកប៉ុក្កង ខាងក្នុងនៃចិត្ត គឺលោកនៃសេចក្ដីបរិសុទ្ធ លោកដែលមានតែសន្តិប៉ុណ្ណោះ សម្រាប់មនុស្សដែលមានសន្តានចិត្តបរិសុទ្ធ រមែងមើលឃើញនរកបានដោយងាយៗ

គម្ពីរពុទ្ធសាសនាជាគម្ពីរដែលមានមកយូរយារណាស់ហើយ តែក្នុងព្រះត្រៃបិដក មានកន្លែងខ្លះបង្ហាញឲ្យយើងឃើញច្បាស់ថាជារឿងដែលបន្ថែមដោយគេចិតាចារ្យក្នុងជាន់ក្រោយជាសទ្ធម្មបដិរូប មិនមែនជារឿងពិតទេ (មើលធម្មវិចារបស់សម្ដេចព្រះមហាសមណៈ ហេតុនេះ រឿងផ្សេងៗដែលមានពោលទុកក្នុងគម្ពីរ នឹងប្រកាន់ថាជារឿងពិតទៅទាំងអស់ក៏មិនបានដូចរឿងនរកនឹងសួគ៌ ដែលមានពោលទុកក្នុងពាលបណ្ឌិតសូត្រនឹងទេវទូតសូត្រនោះ បើនឹងប្រកាន់យកថាជារឿងពិតតាមន័យនោះ ដោយមិនប្រែសេចក្ដីបំណងទៅជាធម៌វិញទេ គង់នឹងឃើញថាជំទាស់គ្នានឹងសេចក្ដីក្នុងគម្ពីរដទៃ ហើយហេតុដែលធ្វើឲ្យធ្លាក់នរកនឹងផលមើលទៅមិនសមគ្នាសោះ ហើយសេចក្ដីត្រង់កន្លែងខ្លះទៅដូចគ្នានឹងរឿងបរម្យា ដែលមនុស្សក្រៅសាសនាគេជឿក្នុងសម័យនោះ ហេតុនេះខ្ញុំក៏មិនអាចនឹងបង្ហាញឲ្យឃើញថា នរកនៅក្រោមដី ស្ថានសួគ៌នៅលើមេឃបានដែរ តែបើនរកនឹងសួគ៌នៅលើលោកយើងនេះមានពិតមែន ព្រោះគម្ពីរក៏បានពោលទុក ហើយសេចក្ដីក្នុងគម្ពីរត្រង់កន្លែងនេះស្របគ្នានឹងហេតុផលក្នុងអរិយសច្ច បច្ចយាការនឹងកម្មដែលជារឿងអាចពិសោធន៍ ឲ្យឃើញពិតបាន ការជឿតាមគម្ពីរ ខ្ញុំប្រកាន់យកគោលថា គួរជឿរឿង

ណាដែលអាចពិសោធន៍ឲ្យឃើញបានសិន ឯរឿងដែលនៅមិនទាន់បានពិសោធន៍ឲ្យឃើញជាក់ច្បាស់ គួរទុកក្រោយសិន ឬមិនជឿក៏បាន តែបើទុកជាដូច្នោះ ក៏ត្រូវបង្អង់ទុកខ្លះសិន ព្រោះរឿងខ្លះជារឿងពិត ៗ យើងមិនជឿមកពីដើម ហើយចេះតែមិនជឿទៅក៏មាន សេចក្ដីពិតផ្សេងៗមិនមែនមានអស់ហើយចំពោះតែរបស់ដែលយើងដឹងប៉ុណ្ណោះទេ ហើយការជឿថា មាននរកនិងសួគ៌ក្រោយពេលដែលមនុស្សស្លាប់ទៅហើយនេះ រមែងរួចចាកភ័យជាងការមិនជឿសោះ ។

ម្យ៉ាងទៀតដោយសារការជឿរឿងនរកនិងសួគ៌នេះ យើងត្រូវអាស្រ័យគម្ពីរជាប្រធាន ដូច្នេះក្នុងការសរសេររឿងនេះ ខ្ញុំបានលើកយកគម្ពីរមកអាងជាផកប តែមានកន្លែងខ្លះប្រែត្រង់ៗទៅមិនយល់ក៏មាន ព្រោះកន្លែងនោះលោកពោលទុកខ្លីៗពេក ឯពាក្យអធិប្បាយមាននៅក្នុងដីកា ខ្ញុំក៏បានតាមទៅដកយកសេចក្ដីខ្លីៗហើយ រៀបរៀងជាថ្មីដើម្បីឲ្យស្ដាប់បានងាយ ដោយអាស្រ័យសេចក្ដីក្នុងគម្ពីរដូចដែលមានពោលតទៅនេះ អស់លោកនឹងបានដឹងជាក់ច្បាស់ថា នរកគឺអ្វី? នៅឯណា? អស់លោកនឹងទៅនរកឬសួគ៌នោះ អស់លោកនឹងជ្រាបបានដោយខ្លួនឯង ។

"ភិក្ខុទាំងឡាយ! ជាលាភរបស់អ្នកទាំងឡាយហើយ! អ្នកទាំងឡាយល្អហើយដែលមានឱកាសមកប្រព្រឹត្តព្រហ្មចរិយធម៌ តថាគតបានឃើញហើយភិក្ខុទាំងឡាយ! នរកនិងសួគ៌មាននៅនឹងអាយតនៈ៦ ដែលជាទីកើតនៃផស្សៈហ្នឹងឯង ក្នុងលោកនោះយ៉ាងណា គឺៈ ក្នុងខណៈណាប្រសព្វ(ប៉ះពាល់)នឹងរូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ដែលជាទីមិនប្រាថ្នាមិនគាប់ចិត្តមិនប្រសព្វ ក្នុងខណៈនេះជានរក ។ ក្នុងខណៈណាដែលប្រសព្វតែនឹងរូប សម្លេង ក្លិន រស ផោដ្ឋព្វធម្មារម្មណ៍ សុទ្ធជារបស់គួរប្រាថ្នា គួរគាប់ចិត្ត ជាទីមិនប្រាថ្នាមិនគាប់ចិត្តមិនប្រសព្វ ក្នុងខណៈនេះជាសួគ៌(សំ.សឡា.) ។

ត្រង់នេះនឹងសូមអធិប្បាយបន្ថែមបន្តិចថាៈនិរយៈតាមទម្លាប់ប្រែថានរក បើតាមរូបសព្ទប្រែថា កន្លែងដែលគ្មានសេចក្ដីសុខ-ចំរើន ។ សួគ៌ ប្រែថា កន្លែងដែលមានអារម្មណ៍ល្អប្រសើរ ពុទ្ធភាសិតនេះសំដៅសេចក្ដីថា នរកនិងសួគ៌ពេននៅនឹងខ្លួនយើង ក្នុងខណៈដែលប្រសព្វនឹងអារម្មណ៍ផ្សេង ៗ បើចិត្តជាទុក្ខឈ្មោះថាធ្លាក់នរក បើចិត្តជាសុខក៏ឈ្មោះថាឡើងឋានសួគ៌ ។ ឯចិត្តជាសុខឬជាទុក្ខនោះ មិនមែនសំខាន់នៅនឹងអារម្មណ៍ទេ គឺសំខាន់នៅនឹងចិត្ត បើចិត្តអប់រំល្អហើយ សូម្បីជួបប្រសព្វនឹងរបស់មិនជាទីប្រាថ្នាមិនជាទីគាប់ចិត្តក៏មិនបង្កឲ្យកើតទុក្ខដែរ ដូច្នេះទើបព្រះសម្ពុទ្ធទ្រង់ត្រាស់ថា

ព្រះសោតាបន្នបុគ្គល បិទផ្លូវអបាយបានហើយ ព្រោះថាលោកទាំងនេះ បើទុកជាលោកមានកិលេស

សល់ខ្លះ ក៏មិនដល់ថ្នាក់ដែលនឹងបណ្ដាលឲ្យកើតទុក្ខ ដែលហៅថាធ្លាក់នរកដែរ ចំណែកមនុស្សដែលមានចិត្តអាបធ្ងន់នេះ ជួនកាលឡើងស្ពត់ ជួនកាលធ្លាក់នរក អ្វីជាភ្លើងនរក? អស់លោកនឹងជ្រាបបានពីពុទ្ធ-ភាសិតដូចតទៅនេះ៖

"ភិក្ខុទាំងឡាយ! ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្តត្រូវភ្លើងដុតកំដៅជានិច្ច អ្វីគឺភ្លើង? រាគៈ ទោសៈ មោហៈ គឺជាគេហៅថាភ្លើង ៗ ជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ គឺជាគេហៅថាភ្លើង (អាទិត្ត.)

នរកដែលមនុស្សធ្លាក់ច្រើនហើយនៅយូរបំផុតគឺអវេចីពាក្យថាអវេចី តាមសព្ទប្រែថា គ្មានទំនេរឬចន្លោះ អធិប្បាយថា រណ្ដៅនរកនេះ គ្មានកន្លែងចន្លោះអណ្ដាតភ្លើងគ្មានទំនេរដោយសត្វនរក មានកំពែងដែកក្រាសរាប់យោជន៍ៗ ទាំងបួនទិស ខាងក្នុងមានភ្លើងឆេះជានិច្ច ហើយមានសត្វនរកនៅពោរពេញ អ្នកដែលធ្លាក់នរកនេះ យូរណាស់ទំរាំបានរួចមកវិញ លុះផុតពីនរកនេះហើយ បើនៅមិនទាន់អស់កម្មត្រូវទៅធ្លាក់នរករណ្ដៅដទៃទៀត សេចក្ដីនេះមានក្នុងអដ្ឋកថាផ្សេងៗដូចយ៉ាង អដ្ឋកថានៃទេវទូតសូត្រជាដើម ៗ យើងគិតមើល! រាងកាយរបស់យើងប្រកបដោយធាតុ៤ ហើយរាងកាយនេះក៏មានភ្លើងដុតកំដៅជានិច្ច បើមិនទាន់អស់កិលេសពីខន្ធសន្ដានដរាបណាដរាបនោះ រាងកាយយើងក៏ត្រូវភ្លើងដុតកំដៅខានមិនបាន សូម្បីស្លាប់ទៅហើយត្រឡប់មកកើតទៀត ក៏ត្រូវដុតកំដៅទៀត យើងគិតមើល! ការដែលនឹងលះកិលេសបានដោយដាច់ខាតនោះលំបាកយ៉ាងណា កាលបើកិលេសមិនទាន់ដាច់ឬជ្រះស្រឡះ យើងក៏ត្រូវកើតទៀតហូរហែទៅហើយនឹងយូរប៉ុន្មានម៉ឺនសែនជាតិនោះយើងក៏កំណត់មិនបានអ្នកដែលកំណត់ជាតិបាន យ៉ាងតូចបំផុតត្រឹមព្រះសោតាបន្នបុគ្គល បុថុជ្ជនត្រូវដុតកំដៅនៅយ៉ាងយូរតទៅទល់តែរាប់មិនអស់កំណត់មិនបាន ដូចព្រះសម្ពុទ្ធទ្រង់ត្រាស់ប្រៀបធៀបថា អ្នកធ្លាក់នរក ទំរាំនឹងបានរួច កំណត់មិនបានថាប៉ុណ្ណោះប៉ុណ្ណោះឆ្នាំ អស់លោកមុខជាសង្ស័យថា ភ្លើងដែលដុតសត្វនរកនោះ ជាភ្លើងអ្វីពិតប្រាកដ ភ្លើងមែនទែនឬក៏ជាភ្លើងកិលេស? អស់លោកនឹងជ្រាបបានពីពុទ្ធភាសិតដូចតទៅនេះ

"គ្មានភ្លើងអ្វីស្មើដោយរាគៈ គ្មានការអាក្រក់អ្វីស្មើដោយទោសៈគ្មានបណ្ដាញអ្វីស្មើដោយមោហៈ" (ធម្មបទ . ភ . ៧)

ពុទ្ធភាសិតនេះសំដែងឲ្យឃើញថា សូម្បីភ្លើងមែនទែន ក៏ក្ដៅមិនដល់ភ្លើងគឺរាគៈដែរ កាលបើដូច្នេះនរកក្នុងលោកនេះ(នរកបច្ចុប្បន្ន)ក្ដៅក្លាឬកាចសា-ហាវជាងនរកមែនទែន ព្រោះភ្លើងក្នុងនរកនោះបើទុកជាមានមែន ក៏មិនក្ដៅដូចភ្លើងរាគៈដែរ ៗ

ម្យ៉ាងទៀត ក្នុងសៀវភៅមាលយ៍ថា "សត្វ

នរកនោះគ្មានបាយសម្លស៊ីទេ” បើដូច្នេះហេតុអ្វីក៏មាននិយាយដល់សាច់ឈាម គូថ មូត្រ តើរបស់អស់នេះបានមកពីណា? លោកបានពោលទុកថា សត្វនរករស់នៅដោយកម្ម មានកម្មជាអាហារកាលបើកម្មនៅមិនទាន់អស់ បើទុកជាស្លាប់ក៏ត្រូវកើតក្នុងនរកដដែលទៀត ស្លាប់កើតៗក្នុងនរកនោះត្រាតែអស់កម្មទើបបានរួចចាកនរកនោះ ។ សេចក្តីត្រង់នេះបើគិតតាមសំនួនអភិធម្មនឹងចូលចិត្តបានងាយ ព្រោះក្នុងអភិធម្មមាននិយាយថា កម្មគឺចេតនាជាបច្ច័យនៃកិលេសទាំងឡាយ, ខន្ធទាំងឡាយកិលេសដែលមិនអស់ទៅក៏ព្រោះកំឡាំងកម្មនៅមិនទាន់អស់ ហើយសូម្បីកិលេសឯងក៏ជាបច្ច័យនៃកម្មដូចគ្នា កិលេស, កម្មនិងវិបាក ទាំង ៣ នេះមួយមុខៗ ក៏សុទ្ធតែជាបច្ច័យដល់គ្នានិងគ្នា ហើយវិលវល់ត្រឡប់ចុះឡើងគ្មានទីបំផុត ដែលក្នុងចន្លោះនៃការវិលចុះឡើងនេះ ពេលខ្លះក៏កើតសោមនស្ស ពេលខ្លះក៏កើតទោមនស្ស តែបើកិលេសឬកម្មមិនអស់ជ្រះស្រឡះចាកខន្ធសន្តានទេ រមែងមានឱកាសដែលនឹងត្រូវបានទទួលនូវទុក្ខជានិច្ច សេចក្តីនេះសមដូចជាលោកពោលទុកថា “សូម្បីតែអ្នកដែលទៅកើតក្នុងឋានសួគ៌ ក៏នៅតែមានពេលត្រូវចុះនរកបានទៀត”

ក្នុងសៀវភៅធម្មវិចារណ៍ របស់សម្តេចព្រះមហាសមណៈមាននិយាយថា “រឿងនរកជារឿងដែលមានមកមុនពុទ្ធកាលក្នុងសាសនាដទៃក៏មាននិយាយដូចគ្នា ហើយរឿងខ្លះស្រដៀងគ្នានឹងរឿងក្នុងគម្ពីររបស់យើង” ក្នុងចូឡខន្ធសូត្រ ព្រះសាស្តាទ្រង់សំដែងសេចក្តីទុក្ខនៃកាមប្រហែលគ្នានឹងទុក្ខដែលមានពណ៌នាទុកក្នុងរឿងនរក ។ មនុស្សដែលជាប់គុកច្រវាក់ ខ្នោះ ឃ្នាង ក៏ព្រោះកាមជាដើមហេតុ ក្នុងមហាទុក្ខក្ខន្ធសូត្រ ព្រះសម្ពុទ្ធទ្រង់ពណ៌នាដល់វិធីដាក់ទោសមនុស្សក្នុងគុកស្រដៀងគ្នានឹងទុក្ខក្នុងនរកដែលមានសំដែងទុកក្នុងពាលបណ្ឌិតសូត្រនឹងទេវទូតសូត្រ ។

(នៅមានត)

---

## ព្រះរាជដំណើរ
## នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
## ទៅកាន់ប្រទេសភូមា

ភ្នំពេញ-ដើម្បីឆ្លើយនឹងសេចក្តីអញ្ជើញនៃលោកផុកទ័របា-អ៊ុយប្រធានសហភាពភូមា, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលមានឯកឧត្តម ឡេង-ង៉ែត ទីប្រឹក្សាឯកជនអមព្រះអង្គ, ឯកឧត្តម ទេព-ផនរដ្ឋមន្ត្រីក្រសួងការបរទេស, ឧកញ៉ាមហាមន្ត្រី ញឹក-ទូ, លោក ឱ-សាត លេខាធិការផ្ទាល់ព្រះអង្គ, លោក ទ្រិញ-ហ៉ញ នាយលេខាធិការដ្ឋាននៃការិយាល័យប្រស្រ័យផ្ទាល់នឹងប្រជារាស្ត្រ និងរាជបរិវារដទៃទៀតអមព្រះអង្គផង, បានស្តេចយាងចេញពីចំណតអាកាស

យានពោធិចិនតុងនៅម៉ោង ៦ ព្រឹកដោយអាកាសយានពិសេសនៃក្រុមអាកាសចរខ្មែរ កូមិន្ទ ។

យើងសូមជំរាបថា នៅម៉ោង ៥ កន្លះព្រឹក ក្រោយដែលទ្រង់បានទទួលការប្រសិទ្ធិជោគជ័យពីសម្តេចព្រះសង្ឃនាយកនិងមន្ត្រីសង្ឃទាំងពីរគណៈ នៅព្រះទីនាំងទេវាវិនិច្ឆ័យតាមប្រពៃណីរួចហើយ, ព្រះកូមិន្ទក៏បានស្តេចយាងចេញពីព្រះបរមរាជវាំងដោយមានព្រះអគ្គក្រមហ្លួងមុនីពង្ស ទីប្រឹក្សាឯកជនអមព្រះអង្គ, ឯកឧត្តមនាយករដ្ឋមន្ត្រី, សមាជិករដ្ឋាភិបាលទាំងអស់, ប្រធានក្រុមប្រឹក្សាជាតិ, អគ្គលេខាធិការ, នាយកមន្ទីរ, ចៅក្រសួង, នាយកាប៊ីណេត, ទីប្រឹក្សា, ចាងហ្វាងសាលាជំរះក្តី, ចៅហ្វាយក្រុងភ្នំពេញ និងចៅហ្វាយខេត្តកណ្តាលតាមដង្ហែព្រះអង្គ



ទៅដល់ចំណតអាកាសយាន ដែលមានលោកស៊ុគ្គូរ៉ាន់ តំណាង លោក ហូតកុម្មីស្សែប្រាំង, អគ្គទូតទាំងអស់, ក្រុមប្រឹក្សាជាតិ, នាយប៉ុយរ៉ូ, ចៅក្រម, មន្ត្រីបំរើរាជការ និងប្រជារាស្ត្រជាច្រើនរយនាក់ រង់ចាំក្រាបថ្វាយបង្គំជូនព្រះរាជដំណើរនោះនេះ ។



ក្រោយដែលទ្រង់បានទទួល ការគោរពក្រុមរក្សាព្រះអង្គ, ក្រុមឆត្រយោធិន និងសស្ស នាយទាហានដែលមានការប្រគំភ្លេងជាតិជាកិត្តិយសរួចហើយ, ព្រះនរបតី ក៏បានទ្រង់លាឥស្សរជនទាំងឡាយ ចេញពីព្រះរាជធានី ។ មានព្រះសង្ឃជាច្រើនអង្គដែលមានព្រះតេជព្រះគុណពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ជាននិមន្តទៅកាន់ប្រទេសភូមាក្នុងថ្ងៃជាមួយ

ដោយអាកាសយានថៃ ។

ព្រះរាជដំណើរទស្សនាការជាមេត្រីភាពនេះមាន រយៈវេលាមួយសប្ដាហ៍ គឺពីថ្ងៃទី ១៥ ដល់ថ្ងៃ២១វិច្ឆិកា ១៩៥៤ ហើយក្នុងឱកាសដែលទ្រង់ប្រថាប់នៅក្នុង ប្រទេសភូមានោះ ទ្រង់ស្ដេចជាអធិបតី នៃការបើក សម័យប្រជុំលើកទីពីរ នៃឆដ្ឋសង្គាយនាដែលធ្វើក្នុង ថ្ងៃទី ១៥វិច្ឆិកា ១៩៥៤ នៅរាជធានីភូមា ។

*

*　　*

## ព្រះរាជដំណើរ

### ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានស្ដេចយាងទៅដល់ក្រុងរង្គូន (ប្រទេសភូមា) ហើយ

---

រង្គូន = ព្រះបាទសម្ដេចព្រះនរោត្ដមសីហនុព្រះ រាជាប្រទេសកម្ពុជាបានស្ដេចយាងទៅដល់ក្រុងរង្គូន កាលពីព្រឹកម្សិលមិញ ដើម្បីបំពេញព្រះរាជទស្សនកិច្ច ជាផ្លូវការចំនួន ១ សប្ដាហ៍ នៅប្រទេសភូមា តាម សេចក្ដីអញ្ជើញ របស់រដ្ឋាភិបាលសហភាពភូមា ។

ព្រះមហាក្សត្រិយ៍ បានស្ដេចយាងចេញ ពីភ្នំពេញតាមយន្ដហោះនៃកងអាកាសចរខេមរភូមិន្ទ ដែលបានទៅចុះនៅចំណតអាកាសយានមិនហ្គាឡាដុន ។ នៅពេលដែលព្រះអង្គយាងចុះពីយន្ដហោះ ទ្រង់ព្រះពស្ដ្រជាឯកសណ្ឋានស ព្រះអង្គបានទទួល សេចក្ដីក្រាបថ្វាយបង្គំ ពីឯកឧត្ដមប្រធានាធិបតី, ពីលោកដុកទ័រ បា-អ៊ុយ, ពីរដ្ឋមន្ត្រីទី ១ អ៊ូ-នូ និងសមាជិកនៃរដ្ឋាភិបាល, នៅពេលដែលកាំភ្លើងបញ្ចេញ សូរសព្ទចំនួន ២១ ណាត់និងបណ្ដាជនជាច្រើនឥត គណនាបន្លឺសំឡេងលាន់រំពង ។

ឥស្សរៈជន ១០ រូបជាយសបរិវារដែលតាម ដង្ហែព្រះមហាក្សត្រមានឯកឧត្ដម ទេព-ផន រដ្ឋមន្ត្រី ការបរទេសប្រទេសកម្ពុជា, ឯកឧត្ដម ខៀង-វ៉ែត ជា ទីប្រឹក្សាឯកជនអមព្រះអង្គ និងឧកញ៉ាមហាមន្ត្រី ញឹក-នូ ជាចាងហ្វាងពិធីការ ។

លុះព្រះអង្គស្ដេចយាងត្រួតពលកងថ្មើរជើង, កងជើងទឹកនិងកងជើងអាកាសរួចហើយ ព្រះមហាក្សត្រិយ៍ស្ដេចយាងឡើងលើរថយន្ត ដែលបើកដំបូល ចេញដោយមានលោកដុកទ័រ បា-អ៊ុយ អង្គុយអមព្រះអង្គផង ដើម្បីទៅកាន់លំនៅស្ថានរបស់ឯកឧត្ដមប្រធានាធិបតី ។

នៅតាមដងផ្លូវចម្ងាយ ១៨ គ.ម. មានពួកសិស្ស សាលា, ពួកកាយរិទ្ធបានឈរធ្វើជារបងកិត្ដិយស កាន់ទង់ជាតិខ្មែរ និងទង់ជាតិភូមាគ្រវីយ៉ាងរីករាយចប់ តែដងផ្លូវ មានចំនួនជាច្រើនពាន់នាក់ ។

នៅពេលរសៀល ព្រះមហាក្សត្រិយ៍គោងស្ដេច យាងទៅទតវត្តសន្តិភាពសាកលលោក, ហើយស្ដេច យាងទៅធ្វើជាព្រះរាជាធិបតីភាពនៃពិធីបើកឱកាស ពេលប្រជុំឆដ្ឋសង្គាយនាលើកទី ៦, ដោយមាន

ឯកឧត្តមប្រធានាធិបតីសហភាពភូមាដង្ហែព្រះអង្គទៅផង ។ នៅពេលល្ងាចព្រះមហាក្សត្រិយ៍ ទ្រង់បើកឲ្យប្រធាននៃគណៈបេសកកម្មទូត និងស្ថានកុងស៊ុល ចូលក្រាបបង្គំគាល់ មុនពេលដែលព្រះអង្គស្ដេចយាងទៅទទួលព្រះក្រយាស្ងាយដែលលោកដុកទ័រ បា-អ៊ូ រៀបថ្វាយ ។

*

* *

## សេចក្ដីនៃបុតហ្មាយរបស់ឯកឧត្តមដុកទ័រ បា-អ៊ូ ប្រធានសហភាពភូមា សុំស្ដេចព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទៅបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសរបស់លោក

ភ្នំពេញ- សេចក្ដីតទៅនេះជាបុតហ្មាយនៃឯកឧត្តម ដុកទ័រ បា-អ៊ូ ប្រធាននៃសហភាពភូមា ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងព្រះចៅប្រទេសកម្ពុជា ដើម្បីសូមស្ដេចទៅបំពេញព្រះរាជទស្សនកិច្ចជាផ្លូវការនៅប្រទេសលោក —

វិមាននៃប្រធាន ក្រុងរង្គូន ថ្ងៃទី ១៣ កញ្ញា ១៩៥៤

ព្រះករុណាថ្លៃវិសេស,

ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីរីករាយយ៉ាងក្រៃលែងនឹងថ្វាយចំពោះព្រះករុណាថ្លៃវិសេសនូវសេចក្ដីសុំស្ដេចយាងជាភ្ញៀវរបស់ទូលព្រះបង្គំជាខ្ញុំ សុំឲ្យព្រះអង្គទ្រង់យាងទៅបំពេញព្រះរាជទស្សនកិច្ចនៅសហភាពភូមា ។

ក្រៅអំពីចំណងដ៏ជិតស្និទ្ធជាប្រទេសជិតខាង, ប្រទេសទូលព្រះបង្គំជាខ្ញុំនិងប្រទេសរបស់ព្រះអង្គបានទទួលវប្បធម៌រួមគ្នានិងសាសនារួមគ្នាជាច្រើនសតវត្សណាស់មកហើយ ។ គឺដោយយកចិត្តទុកដាក់បំផុតនិងដោយចិត្តកោតសរសើរយ៉ាងក្រៃលែងដែលពួកទូលព្រះបង្គំជាខ្ញុំបានតាមមើលការប្រយុទ្ធដ៏ក្លាហានដែលប្រទេសកម្ពុជាស្ថិតនៅក្រោមព្រះរាជកិច្ចដឹកនាំនៃលំអងធូលីព្រះបាទបានបំពេញដើម្បីអធិបតេយ្យភាពយ៉ាងបរិបូណ៌របស់ខ្លួន និងដើម្បីឯករាជ្យភាពយ៉ាងពេញលេញរបស់ខ្លួន ក្នុងចំណោមប្រជាជាតិនានា ។

ទូលព្រះបង្គំជាខ្ញុំ មានសេចក្ដីជឿជាក់ថាព្រះរាជទស្សនកិច្ចនៃព្រះករុណាថ្លៃវិសេសពុំមែនគ្រាន់តែធ្វើឲ្យចំណងវប្បធម៌និងសាសនាដ៏ពិតតែជិតស្និទ្ធតែយ៉ាងនោះទេ គឺថែមទាំងធ្វើឲ្យមានតទៅកាន់ការផ្ទះជាលខាងសហការជាមិត្តភាពរវាងប្រទេសរបស់ព្រះករុណាថ្លៃវិសេសនិងប្រទេសទូលព្រះបង្គំជាខ្ញុំរឹងប៉ឹងឡើង ហើយនឹងធ្វើឲ្យសន្តិភាពក្នុងសាសនារបស់យើងមានខ្លឹមសារ

ទូលព្រះបង្គំជាខ្ញុំរង់ចាំទទួលនៅឱកាសដែលព្រះករុណាថ្លៃវិសេស សព្វព្រះរាជហឫទ័យជ្រើសរើសដើម្បីបំពេញព្រះរាជទស្សនកិច្ចនៅសហភាពភូមា ។

សូមក្រាបបង្គំទូលដោយស្មោះចំពោះ

ទូលព្រះបង្គំជាខ្ញុំ ដុកទ័រ បា-អ៊ូ

ប្រធាននៃសហភាពភូមា

## ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ថ្លែង តបវិញតាមព្រះរាជសារលិខិតដូចតទៅ ៖

ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះចៅប្រទេសកម្ពុជា ជំរាបមកលោក បា-អ៊ូ ប្រធាននៃសហភាពភូមានៅក្រុងរ៉ង់ហ្គូន ។

លោកប្រធាន,

តាមលិខិតចុះថ្ងៃទី១ កញ្ញា ១៩៥៤ លោកបានពេញចិត្តនឹងអញ្ជើញខ្ញុំឲ្យបំពេញទស្សនកិច្ចតាមផ្លូវការនៅប្រទេសរបស់លោក ។ ខ្ញុំមានព្រះរាជហឫទ័យរំជួលដោយស្មោះស្ម័គ្រចំពោះចេតនាវិសេសរបស់លោកនេះ ។

គឺដោយមានព្រះរាជហឫទ័យរីករាយបំផុតដែលខ្ញុំទទួលសេចក្តីអញ្ជើញដ៏ស្មោះស្ម័គ្ររបស់លោក ។ ខ្ញុំមានព្រះរាជហឫទ័យជឿជាក់ថា សេចក្តីអញ្ជើញនេះនឹងបើកឲ្យប្រទេសយើងទាំងពីរនូវឱកាសមួយថ្មី ឲ្យយើងនឹងរឹតតែស្គាល់គ្នាឡើង ដើម្បីតចំណងវប្បធម៌និងសាសនា ដែលចងប្រទេសយើងទាំងពីរហើយ ដែលគង់វង់នៅជានិច្ច ជាច្រើនសតវត្សរ៍ណាស់មកហើយ ទុកណាជាមានព្រឹត្តិការណ៍ តាមកាលៈទេសៈដូចម្តេចក៏ដោយ ។

ម្យ៉ាងទៀត ខ្ញុំមានព្រះរាជហឫទ័យរំជួលតាមរបៀបលោកនិងសហភាពភូមាយកចិត្តទុកដាក់នឹងការប្រយុទ្ធដ៏ក្លាហាននិងពលីកម្មរបស់ប្រទេសកម្ពុជាក្នុងការប្រឹងប្រែង ដើម្បីទាមទារយកអធិបតេយ្យភាពដ៏បរិបូណ៌របស់ខ្លួនមកវិញ និងដើម្បីទ្រទ្រង់សន្តិភាពនៅទ្វីបអាស៊ីប៉ែកអាគ្នេយ៍ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមាំថា ការទស្សនកិច្ចរបស់ខ្ញុំនៅពេលខាងមុខនេះ ដែលនឹងធ្វើបន្ទាប់ពីពេល ដែលសហភាពភូមាទទួលស្គាល់ប្រទេសកម្ពុជា និងទស្សនកិច្ចរបស់ខ្ញុំនេះហើយបើកសករាជមួយថ្មី ខាងបំពេញសហការយ៉ាងជិតស្និទ្ធ រវាងប្រជាជាតិយើងទាំងពីរ ។

ដោយហេតុមានពិធីជាប្រពៃណី ដែលនឹងមានធ្វើបន្ទាប់គ្នាក្នុងពេលឆាប់ៗនេះនៅប្រទេសកម្ពុជា, ខ្ញុំមានបំណងចង់ឲ្យដំណើរខ្ញុំ នឹងមានឡើងនៅអឌ្ឍមាសទីពីរនៃខែវិច្ឆិកា ១៩៥៤ ។

ទាំងនឹងមានសេចក្តីរីករាយ នឹងជួបជាមួយលោកប្រធាន ខ្ញុំសូមឲ្យលោកទទួលសេចក្តីបញ្ជាក់នៃសេចក្តីរាប់អានដ៏ឧត្តមបំផុតរបស់ខ្ញុំ ។

ព្រះបរមរាជវាំង ថ្ងៃទី៧តុលា ១៩៥៤

ព្រះហស្តលេខា ៖

នរោត្តម-សីហនុ

# មិត្តសប្បុរសនឹងកតញ្ញូ



កាលព.ស. ២៤៩០, ក្នុងរដូវមានភ្លៀងធ្លាក់ចុះជោគជាំស្រោចស្រប់លើពសុធា, ព្រះទិនករស្រទន់ត្រជាក់បញ្ចាំងពោលរស្មីពណ៌មាសពាសមកលើវត្ថុទាំងអស់ដែលមានប្រចាំពិភពលោកទាំងមូល, រុក្ខាលតាវល្លិទាំងឡាយ មានសន្លឹកលាស់ខៀវខ្ចីបញ្ចេញគន្ធពិដោរក្រអូបឈ្ងុយឈ្ងប់បណ្តែតតាមកំលាំងព្រះពាយស្រស់បំព្រងតាមលំអធម្មជាតិ, សព្វសត្វនិករ មានសេចក្តីសប្បាយរីករាយសមរសយ៉ាងក្រៃលែង, នៅចំការលើទីរួមខេត្តកំពង់ចាម មានព្រានព្រៃពីរនាក់ឈ្មោះលន់១ មា១ជាមិត្តជិតដិតបានបាវគ្នាពីរៀងអតីតកាលគ្រប់សម័យ ដៃមានបុគ្គលពារើយនឹងបានចេញចរចាកគេហដ្ឋានចូលទៅកាន់អរញ្ញ-ប្រទេស ដើម្បីរកសត្វឃាតយកសាច់ប្រែជាលុយផលនៃការបាញ់នោះមកចិញ្ចឹមជីវិតជូនភាគីនៃក្រុមគ្រួសារ, លុះពិគ្រោះពិចារណាទៅ ក៏យល់ស្រប គំនិតគ្នាជាឯកច្ឆន្ទតាមគន្លងហោរាសាស្ត្រ(១)ថា ថ្ងៃស្អែកនេះ ជាថ្ងៃមានបុគ្គលល្អ គួរយើងចេញទៅស្វែងរកបាញ់បាន ហើយក៏បែរមកផ្តាំផ្ញើប្រាប់ប្រពន្ធរៀងខ្លួនឲ្យរៀបប្រដាប់ប្រដាអាហារនោះជន មានអង្ករត្រីងៀត អំបិល ជាដើម ឯខ្លួនឯងក៏ចាត់ចែងធ្នូ ស្នាព្រួញ កាំបិត រណារ ប៉ូវថៅ កៅទណ្ឌ និងកាំភ្លើង (សម្រាប់បាញ់សត្វ) រួចស្រេចបាច់តាំងពីព្រឹកព្រលឹមម៉្លេះ ។

លុះពេលបច្ចូសសម័យ អរុណោទ័យមានរស្មីភ្លឺរៀងៗនាទិសបូព៌, ព្រានទាំងពីររូបក៏ក្រោកអំពីដំណេក ហើយគាត់យកប្រដាប់ប្រដាអម្រែកអម្រែអាហារទឹកធ្នូស្នាជាដើម ដែលរៀបចំស្រេចនោះ ចរយាត្រាសំដៅទៅកាន់ព្រៃ តាមពេលដែលសន្មតគ្នាយ៉ាងលឿន ឆ្ងាយពីភូមិលំនៅដ៏ស្រយាល ដរាបដល់ពេលថ្ងៃត្រង់ ក៏ឈប់សម្រាកកំលាំងដើម្បីបរិភោគអាហារបាយនៅក្រោមម្លប់ឈើត្រឈៃត្រឈៃ លុះបរិភោគរួចកាលណាក៏ជេសវៃប្រះគាត់ដេកសម្រាកនៅទីនោះ អស់រយៈពេលប្រហែលពីរម៉ោង ទើបក្រោកចាកនិទ្រាហើយចរយាត្រា គាត់ព្រៃក្នុងតំបន់ទាំងឡាយដើម្បីស្វះស្វែងបាញ់សត្វនៅកណ្តាល

(១)តាមជំនឿ ព្រានព្រៃខ្មែរតែងតែចេញទៅបាញ់តែងតែទុកឃកតាមតម្រាហោរាសាស្ត្រមាណ ។

ព្រហារណ្យស្ងាត់សម្ងំមនុស្ស មានតែសម្លេងបក្សី តាំងឡាយគឺៈ ក្អែក ក្រួច ករវិក តុក ខ្វែក ត្រលីងត្រលោង ក្រៀល ក្អែក ចចាត ចាក្រពាក ព្រហ៊ីត ឡៀបកញ្ជាស ត្រដក់ ត្រដេវិច បរគាវ អក ចោលតោករលក រពាំងព្រៃ មានទឹក មានពោរ មៀម ទីទុយ សត្វា សារិកា សេកយាវជាដើម យាសយំឡើយដូចគ្នា ឮហឹងអឹងកងរំពងពេញព្រឹក្សា ពិរោះលន្លង់លន្លោច ធ្វើឲ្យព្រះទស្រងេះស្រងោចជា យ៉ាងក្រៃលែង ៗ ព្រានឈ្មោះលទ្ធកស្រែកច្រៀង យ៉ាងពិរោះគួរឲ្យស្រណោះអាសូរក្នុងព្រៃនោះថា :

ទ៎ះទុកមម្អីកាគ្នាឯង កកើតចំបែងក្នុងចិត្ត ត្រាប់ បរពាកញាតិក្នុងព្រឹក្សា លន្ទង់ខ្មោចផ្សាពន់ប្រមាណៗ មិនដឹងស្លាប់រស់ប្តូយ៉ាងណា ព្រោះហេតុអាត្មាយាត្រា ឋាន ចូលក្នុងព្រឹក្សព្រៃវេហាស្ថាន ជាព្រៃសមសាន្ត បរបាញ់សត្វ ៗ លេចកាលចូលព្រៃស៊ើរក្សៀយប្រាណ កម្លាំងប៉ុន្មានហេវពេកក្លាត់ ដើរដោយព្រៃក្នុងហៅ សែនស្ងាត់ពុស្សូវតែសត្វយំឡើយគ្នា ៗ ទើបព្រាន បែមករកមិត្តភក្តិ យើងទាំងពីរនាក់វង្វេងវងេទា ចាប កម្ពៃរយើងរង់វេក ចូលក្នុងអាគ្គាសូខ្យស្ងាត់ឈឹងៗ ខ្ទះយើងនេះឯងឃ្លាតញាតិឆ្ងាយ កម្មកាយឲ្យពៀរ អាក្រក់ម៉ុង ដើរចូលក្នុងព្រៃស្ងាត់បែបហ្នឹង មិនដឹង យើងសាងកម្មបែបណា ៗ នៃគៀនចូរមើលស្វាយ ក្រសាំង ក្នុងក្នុងខ្វរណាំងទឹងបាយស្រោ លំពាន់ ក្រដាន់ដើមត្រៀលស្វា ចន្ទន៍ជួយចារពន្ធ្រេញ ៗ ស្វែងស្តុកស្តុរទឹងដើមប៉ុសនាគ ពុទ្រាផ្លែព្រាកដើម បន្ដៅ មន្ទ្បូតលុតលើរល្អពេកក្លូវ ដុះនៅក្បែរជើង នៃបព្វតា ៗ មើលចុះមើលចុះឈើទាំងអស់ ស្ទឹក បំព្រងស្រស់ខ្វះមានផ្កា ខ្វះទៀតមានផ្លែសំយុងស្លា គួចង់ទស្សនាពន់ពេកក្រៃ ៗ គន់ៈមើលទៅមេឃ វែងអន្ទាយ វែងឆ្ងាយលន្ទោចគួរកាល័យ មើលក្តីក្តី ខ្ពស់យ៉ាងស្កឹមស្កៃ មើលព្រៃព្រៃដុះពាសត្រៀបត្រា នៃគៀនយើងរំយាត្រាមក ចូលជ្រកក្នុងព្រៃនេះឯង ណា ដើម្បីបរបាញ់សត្វបក្សា ដោយធ្មឹងស្មាណា មិត្រអើយ ៗ

អកព្ទអ្វីថ្ងៃនោះ, ព្រានទាំងពីរ, កាលចូលទៅ ក្នុងព្រៃជ្រៅ , ពុំឃើញមានសត្វណាមួយដែលគួរ បាញ់សោះ ហើយដើរហួសពីព្រៃនោះទៅកាន់ទី វាលប្រហែលជាពីរគីឡូម៉ែត្រ ក៏បានជួបប្រទះដំរីមួយ នៅក្រោមដើមស្វាព្រាមដែលមានមែកសាខាស៊ុមទ្រុម សំយុងចុះមកក្រោមនៅសល់ចន្លោះល្មមដំរីចូលទៅ ជ្រកបានដោយស្រួលទឹងប្រកបដោយម្លប់ត្រឈឹងត្រ ឈៃ ៗ កាលដំរីឈរព្រងើយនៅក្រោមដើមស្វា ព្រាមនោះ ព្រានលបពួនមើលពីក្រោយឃើញ ពស់ថ្លាន់មួយយ៉ាងធំ កំពុងសម្រក់ទឹកមាត់ដាក់ លើខ្នងដំរី ហើយតួនតួចក្បាលទឹងប្រមែកឈើនោះ បានពីរបន្លាយ ៗ ឯដំរីកាលទឹកមាត់ពស់ថ្លាន់ហូរធ្លាក់ មកលើខ្នង ទឹកស្នានបាជាទឹកឈុម្ភតាពុំបានពិចារណា រកហេតុផលសោះ បណ្តោយឲ្យទឹកនោះហូរធ្លាក់មក

លើយ៉ាន់ត្រជាក់ស្រួលក្រៃលែង ក៏ឈរផ្ញើរហើយហាក់ដូចជាពុំមានសេចក្ដីតក់ស្លុតនឹងទុក្ខហេតុដែលបំរុងកើតមានដល់ខ្លួន ។ មិនយូរប៉ុន្មានពស់ថ្លាន់ក៏ទម្លាក់កន្ទុយពីមែកឈើបន្តិចម្ដងៗឲ្យរួលទាន់ក្រោមពោះដំរីដោយមិនឲ្យដឹងខ្លួន ដកបដល់ពីរបានមួយជុំ ហើយរឹតដំរីនោះយ៉ាងជាប់ណែន មិនឲ្យដើរទៅណារួច ។ ដំរីដឹងថាមានគេរឹតមកកើតហេតុដល់ខ្លួនជាពិតប្រាកដដូច្នោះ ខំប្រឹងប្រែងធ្វើខ្លួនឲ្យរួចចាកចំណងមរណភ័យនោះ តែឥតប្រយោជន៍សោះពស់ថ្លាន់នៅតែរឹតជាប់ដដែល ។ កាលដំរីប្រឹងទាញម្ដងៗមែកស្វាត្រាយមិនអាចទប់នឹងកំលាំងដំរីបានក៏ពត់ទន់ចុះមក, ឯដំរីវិញ ហើបជើងមុខទាំងគូ ទំងន់មានអស្សុជលហូរចេញសស្រាក់ពីនេត្រា ដោយមិនដឹងរិះរកមធ្យោបាយបែបណា នឹងធ្វើឲ្យរួចចាកចំណងមរណភ័យនោះ ។

គួរឲ្យអាណោចអធ្មករុណាគតាសូរដំរីណាស់កាលរើពីចំណងពស់ថ្លាន់មិនរួច ក៏បន្ដឹងផ្ញើយ៉ាងណា យកប្រមោយទៅវាយប្រហារលើខ្លួនពស់ថ្លាន់ ៗនៅតែមិនរបោ ខំទាញអស់កំលាំងជាច្រើនដងក៏មិនរបូតដោយអស់សង្ឃឹមនឹកស្មានថាប្រហែលជាស្លាប់ដោយសារពស់កំណាចនេះហើយមើលទៅ ម្ល៉ោះហើយក៏មានតែទឹកភ្នែកជាទីពឹង គឺស្រក់បង្ហូរទឹកភ្នែកមកលើ ព្រះធរណីដោយឥតស្រាកស្រាន្ត (បើប្រសិនជាមនុស្សយើងវិញ ពេលជាប់ចំណងសេចក្ដីស្លាប់ដូច្នេះ មុខជាទ្រហោយំលាន់ឮក្ដែងៗ បណ្ដាលឲ្យអ្នកស្ដាប់-ឮ សម្រក់ទឹកភ្នែកតាមដោយអាណិតអាសូរជាមិនខាន) តែដំរីជាសត្វតិរច្ឆានមិនអាចនឹងថ្លែងអំនួតដូចម្ដេច ដើម្បីឲ្យពស់ថ្លាន់អាណិតអាសូរ, បើនឹងហានិយាយអង្វរករឲ្យលែងក៏និយាយមិនកើត ម្ល៉ោះហើយក៏មានតែការថ្ងូរផ្ដើសចុកណែនពោរពេញទៅដោយសេចក្ដីទុក្ខតង់ដើមទ្រូង ស្ទើរនឹងរបេះទៅជាខ្ទាត, ចំណងពស់ថ្លាន់កាន់តែរឹតខ្លាំងឡើងៗតាមលំដាប់ ឥតមានគ្រាប្រណីដល់ដំរីជាសត្វតិរច្ឆានផងសោះ ។

កាលព្រានទាំងពីរនាក់លបមើលឃើញដូច្នោះ, ព្រានឈ្មោះម៉ាជាមនុស្សពួរជាតិច្រើនស្ដីស្ទួរអបលគុណមិនមានចិត្តមេត្តាដល់ដំរីផងនោះ និយាយថា: ត្រូវ

(មានត)

---

# សិល្បៈនិងអតីតនៃព្រះរាជអាណាចក្រខ្មែរ

លោកហង់រីម៉ាសាល់ ( **Henri Machal** )

អតីតរក្សាក្រុមប្រាសាទអង្គរជាអ្នករៀបរៀង លោកព៍យ-ប៊ុត ក្រុមការទៅឃោសនាការប្រែជាភាសាខ្មែរៗ

សុវិល័យខ្មែរបូរាណ អាចមានតម្លៃស្មើគ្នានឹងសុវិល័យប្រទេសឯទៀត ដែលបានទុកអនុស្សាវរីយ៍គន្ថប្រវត្តិសាស្ត្រលោក ។ សុវិល័យនេះមានក៏ស្ដ-

តាំងក្នុងសម័យបច្ចុប្បន្ន គឺប្រាសាទដែលស្ថិតនៅពាសពេញក្នុងផែនកម្ពុជរដ្ឋ ។

ប្រាសាទទាំងអស់នោះមានតែប្រាសាទដែលសាងនៅខាងជើងបឹងទន្លេសាបដែលគេហៅថាប្រាសាទអង្គរ តែងមាននាមល្បីល្បាញជាងគេ ។ ប្រាសាទអង្គរនេះ បណ្ឌិតខាងបូរាណវត្ថុទើបនឹងស្រាវជ្រាវឃើញស្គាល់ច្បាស់តាំងពីជាង ៥០ ឆ្នាំមុននោះ ។

ពីអតីតកាល ប្រាសាទនេះមានពួក អឺរ៉ុប អៀងជាទ់ជាតិពរទុយគេស៍ និងអេស្ប៉ាញ៉ុលបានមកទស្សនាការពីសតវត្សទី ១៦ និង ១៧ តែរឿងនេះបាត់ស្ងាត់ឈ្ងប់ហើយគ្មានអ្នកណាយកចិត្តទុកដាក់សោះឡើយ, មានការគមនាគមន៍នៃអ្នកដំណើរជាតិចិនម្នាក់នាម "តូ-តាគួន" បានមកដល់ប្រាសាទអង្គរក្នុងសតវត្សទី ១៣ រាយរ៉ាប់រឿងរ៉ាវនេះច្បាស់លាស់ អំពីព្រះបរមរាជវាំងនិងជីវភាពនៃប្រជារាស្ត្រខ្មែរក្នុងសម័យនោះ ។ រឿងនេះមានលោកអាបែលរ៉េមុយសាត ( Abel Remusat ) បានប្រែជាភាសាបារាំងពីសតវត្សទី ១៩ ក្រោយតមកមានលោកប៉ូលពេលីយ៉ូត(Paul Pelliot ) ។



ប្រាសាទអង្គរវត្ត

ពី គ.ស ១៨៦១ មានវិញ្ញាជនបារាំង លោកហង់ មូហូត៍ (**Henri mouhot**) ដោយបានឃើញប្រាសាទអង្គរនៅក្នុងព្រៃ បានប្រកាសសរសើរអំពីអច្ឆរិយវត្ថុនៃអតីតខ្មែរទៅនៃប្រទេសបារាំង ។

តាំងពីនោះមកការស្រាវជ្រាវរឿងនេះក៏កាន់តែបានផលល្អឡើង មានកិច្ចទស្សនាការនៃប្រាសាទនេះកញ្ញឹកញ្ញាប់ ហើយបេសកកម្មក៏ត្រូវធ្វើឡើងជាលំដាប់តមក ការស្រាវជ្រាវព្រមទាំងកិច្ចសិក្សានូវអតីតប្រវត្តិប្រទេសកម្ពុជា ។

ការដែលមានចំនួនច្រើននិងក្បាច់សិល្បៈប្រកបដោយអច្ឆរិយភាពនៃប្រាសាទដែលស្ថិតនៅគ្រប់និគមជនបទប្រទេសខ្មែរបញ្ជាក់ឲ្យឃើញថា នៅទីនេះមាន

ប្រជារាស្ត្រដ៏ឧត្តុង្គឧត្តមមួយរស់នៅពីអតីតកាល ។

ការប្រែអក្សរក្នុងសិលាចារឹកដែលបានរកឃើញនៅប្រាសាទទាំងនោះ នាំឲ្យស្គាល់បានចំពោះប្រវត្តិសាស្ត្រនៃប្រជារាស្ត្រដ៏វិសេសវិសាល ដែលជាអ្នកសាងប្រាសាទទាំងប៉ុន្មាន ព្រមទាំងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ដែលសោយរាជ្យក្នុងសម័យនោះ ។

យើងអាចដឹងបានច្បាស់លាស់នូវសន្តតិវង្សមហារាជទាំងនោះ ព្រះរាជជីវភាពនិងសង្គ្រាមដែលកើតមានឡើងក្នុងសម័យនោះ ។

ខ្ញុំនឹងពណ៌នាដោយសង្ខេបនូវប្រវត្តិសាស្ត្របុ-រាណនៃកម្ពុជរដ្ឋដើម្បីនឹងឲ្យលោកអ្នកជ្រាបអំពីរឿងរ៉ាវទាំងនោះ ដែលមានសៀវភៅជាច្រើនពិពណ៌នាវិត្ថារពិស្តារ អំពីប្រទេសកម្ពុជាក្នុងអតីតសម័យ ។

កាលសម័យដែលព្រះរាជអាណាចក្រខ្មែរមានសភាពរុងរឿងជាងគេនោះ គឺតាំងពីសតវត្សទី ៦ ទៅដល់សតវត្សទី១៤ កាលសម័យដែលសៀមចូលទៅលុកលុយបំផ្លាញឥទ្ធិពលនៃប្រទេសកម្ពុជាជាបរិយោសាន ។

ព្រះរាជអាណាចក្រខ្មែរពីសម័យបុរាណមានព្រំដែនវែងឆ្ងាយធំទូលាយ, ធំសម្បើមអស្ចារ្យ, គេបានរកឃើញប្រាសាទជាច្រើន ដែលខ្មែរសាងនៅប្រទេសសៀមលាវ និងវៀតណាមខាងត្បូង ។

មុននឹងឡើងទៅកាន់ឧត្តមភាពជាខាងដើមនៃសតវត្សទី ៦, ប្រទេសកម្ពុជាជាប្រទេសនៅក្នុងព្រះរាជអាណាចក្រមួយហៅថា "ហ្វូណន់" ប្រកបដោយសិរីល័យមាំមួន តែគេមិនសូវបានដឹងរឿងរ៉ាវប្រទេសនេះពីកាលសម័យនោះឡើយ ។ ដំណឹងសំខាន់ៗអំពីរឿងនេះ គឺមកពីមានពួកចិនដែលបានធ្វើដំណើរទៅមកទាក់ទងនឹងព្រះមហាក្សត្រិយ៍ "ហ្វូណន់" ។ តែបើតាមការជីកកាស់នូវបុរាណវត្ថុធ្វើនៅទន្លេបាសាក់ (ភូមិភាគក្រមួនស ក៉ែ យ៉ា) បានបញ្ជាក់ឲ្យឃើញថាប្រទេស "ហ្វូណន់" មានការគម-នាគមន៍និងប្រទេសខាងមជ្ឈិមទ្វីបហើយនិងព្រះរាជអាណាចក្ររ៉ូម៉ាំង ។

គេអាចយល់ច្បាស់ថាពីសតវត្សទី ១ នៃគ្រិស្តសករាជ មុខជាមានអ្នកដំណើរពួកបួសនិយេសក៍ (Pelerins) និងពួកពាណិជ ... ។ល។ ជាច្រើនចេញចូលទៅមកនៅឧបទ្វីបឥណ្ឌូចិន ។

ក្នុងសតវត្សទី ៦ មានរដ្ឋមួយក្នុងចំណោមនៃរដ្ឋដែលនៅក្រោមអនិស្សរភាពប្រទេស "ហ្វូណន់" ព្យាយាមតាំងខ្លួនជាឯករាជ្យពេញទីបាន, ហើយតាំងពីកាលនោះមកប្រទេសកម្ពុជា ក៏មានកេរ្តិ៍ឈ្មោះក្នុងប្រវត្តិសាស្ត្រលោក ។

អាណាចក្រនៃប្រទេសកម្ពុជាក៏មានសាងប្រា-សាទពាសពេញ ដើមដំបូងមានសភាពធម្មតា មានច្រើនធ្វើពីឥដ្ឋក្រោយធ្វើពីថ្មបាយក្រៀមណាស់ ដែលគេបានឃើញកំសួលផ្សាយពីសិល្បៈឥណ្ឌាដែលមានសិរីល័យនិងពុទ្ធសាសនា ព្រហ្មញ្ញសាសនាផ្សាយ

ខ្មៅគង់បួនពាក់ទ្វីប ។

ព្រះមហាក្សត្រិយ៍ខ្មែរជាបឋមបាន ស្ថាបនានូវព្រះរាជធានីនិងព្រះរាជវាំងក៏បានជាច្រើនកន្លែង, មានខ្លះស្ថិតនៅឆ្ងាយពីគ្នា គេបានស្រាវជ្រាវឃើញដោយមានកេរ្តិ៍តំណែលព្រមតាំងសិលាចារឹកដែលមានតាំងកាលបរិច្ឆេទត្រាទុកនោះផង ។

ព្រះរាជធានីដំបូងពីបុរាណសម័យបានទុកកេរ្តិ៍តំណែលប្រាសាទជាច្រើនគឺព្រះរាជធានីសម្បូណ៌ព្រៃគុក ខាងជើងខេត្តកំពង់ធំដែលព្រះបាទឥសានវរ្ម័នសាងពីសតវត្សទី ៧ ។

ក្រោយមកមានកាលសម័យប្រកបដោយការកន្លស់ជាច្រើនដែលមានព្រះរាជអាណាចក្រចែកទៅជាពីររដ្ឋ គឺកម្ពុជាគោកខាងជើង និងកម្ពុជាទឹកខាងត្បូង ។ ឯកភាពនៃរដ្ឋទាំងពីរនេះបានសម្រេចនូវរដ្ឋកាលព្រះបាទជ័យវរ្ម័នទីពីរដែលសិលាចារឹក ពោលថាស្តេចយាងមកពីប្រទេសជ្វា ។ ព្រះមហាក្សត្រិយ៍អង្គនេះសោយរាជ្យបាន ៥២ វស្សាពី គ.ស. ៨០២ ទៅ គ.ស. ៨៥៤, ទ្រង់បានស្ថាបនាព្រះរាជធានីជាច្រើនកន្លែង ។ ទីមួយហៅថាឥន្ទ្របុរៈ, ប្រហែលជានៅខាងកើតកំពង់ចាមរួចមកជាប់នឹងទន្លេសាប, ទ្រង់បានសាងព្រះរាជធានីហៅថា "ហរិហរាល័យ" នៅស្រុករលួសជិតខេត្តសៀមរាប ។

ព្រះរាជធានីទីបីហៅថា អមរេន្ទ្របុរៈបានស្ថាបនាខាងលិចអង្គរ នៅត្រង់កន្លែងដែលគេបម្រុងនឹងជីកស្រះបារាយណ៍ខាងលិចតទៅអនាគត, ព្រះរាជធានីជាអវសាននៃព្រះបាទជ័យវរ្ម័នទីពីរ គឺមហេន្ទ្របវ៌ត: គេបានស្រាវជ្រាវឃើញស្ថិតនៅលើភ្នំគូលេនខាងជើងអង្គរ ។ គឺព្រះមហាក្សត្រិយ៍អង្គនេះដែលបានសម្មតិនាមទ្រង់ថា "ទេវរាជ" ព្រះអាទិទេពស្តេច (Dieu Roi)

( មានត )

# បញ្ហាពោលអំពីមនុស្សស្បែកខ្មៅ (ត)

(តពីលេខ ១០ មក)



សង្គមរបស់ពួកនេះ មិនត្រូវកើតមានបានក៏ដោយអាស្រ័យមានការប្រតិបត្តិច្បាប់លទ្ធិប្រជាធិបតេយ្យ និងការសិក្សាប្រកបដោយចិត្តអំណត់និងស្តាប់គ្នាបាននៃក្រុមគ្រួសារទាំងឡាយតៗគ្នាមក ។

ចម្បាំងអស់រយៈពេលជាយូរនេះ បានបំផ្លាញឲ្យវិនាសហោចនូវសេដ្ឋកិច្ចកសិរដ្ឋទិសខាងត្បូង ។ ការវិនាសបាកតាសភាពរបស់ខ្លួន ជាចម្ងន់មួយហាង

សមៀមដល់ពួកជនជាម្ចាស់កម្មសិទ្ធិនៃរបរដំណាំទាំងឡាយរកែកមិនឡើង ដ្បិតជាបើគ្មានទាសៈទាំងនោះហើយ របៀបកសិកម្មសម័យចាស់មិនអាចដើររួចទៀតវិញបាន ។ របៀបការចិញ្ចឹមជីវិតក្នុងរដ្ឋទិសខាងត្បូងដូចសម័យដើមក៏ផុតត្រឹមនោះ ហើយប្រជាជនទាំងឡាយក្នុងតំបន់នោះ រមែងរក្សានូវការជូរចត់ចិត្តខ្វះនៅក្នុងខ្លួនចំពោះរឿងខាងលើនេះ ។ សេចក្តីជូរចត់ចិត្តភាគច្រើនបានធ្លាក់ទៅលើពួកជាតិណែក (មនុស្សស្បែកខ្មៅ) ដែលជាគោលដម្រូវនៃសេចក្តីទុក្ខរបស់ខ្លួនក្នុងសេរីភាពដែលទើបបានមកថ្មីៗនេះ ។ ពីម្យ៉ាងវិញ ពួកស្បែកសត្រួតពីលើពួកស្បែកខ្មៅក្នុងថ្ងៃនេះចំការទាំងឡាយត្រូវគេបោះបង់ចោល របងរលំអស់មានផ្ទះធំៗជាច្រើន ដល់នូវសេចក្តីវិនាស ។ ទៅហាយចាស់ មានទ្រព្យសម្បត្តិមិនច្រើនជាងខ្ញុំកំដររបស់ខ្លួនឡើយ ។

ប៉ុន្តែបើពួកស្បែកសមានសេចក្តីព្រួយ ពួកស្បែកខ្មៅក៏ព្រួយដែរ ។ ខ្លួនមិនអាចធ្វើមុខរបរអ្វីមួយបានដោយស្រួលឡើយ ព្រោះខ្លួនមិនចេះអក្សរ ។ ដោយមិនមានចំណេះខាងសិប្បយការ ម្ល៉ោះហើយកាលដែលខ្លួនធ្វើនិក្ខបវេសន៍ទៅក្នុងតំបន់សិប្បយការខាងជើង ខ្លួនត្រូវតែទទួលធ្វើរបរខាងហត្ថកម្មដែលខ្លួនធ្លាប់ចេះ ។ ដោយខំហាត់ឲ្យទៅជាម្ចាស់នៃកម្មសិទ្ធិក៏ជនជាតិស្បែកខ្មៅភាគតិចណាស់ដែលមានដីធ្លីដើម្បីនឹងធ្វើ ។

ពួកអ្នកកាន់កាប់រដ្ឋការអាមេរិកាំង យល់ថា-បើជាតិណែកក្លាយទៅជាពលរដ្ឋពិតប្រាកដដែរតាមច្បាប់ហើយ នោះគេនឹងត្រូវការខាងកិច្ចសិក្សាជាមិនខាន ។ គេក៏បង្កើតសាលាជាពិសេសសំរាប់ពួកជាតិណែក នៅក្នុងតំបន់ទិសខាងត្បូងដូច្នេះទើបមានអគ្គការបែកគ្នាដែលមានទៅរហូតមកដល់សព្វថ្ងៃនេះ ។

ក្នុងឆ្នាំ ១៨៧០ គឺ ៥ ឆ្នាំជាខាងក្រោយសង្គ្រាម មានជាតិណែកចំនួន ៣០ភាគរយចេះអានអក្សរ ។

ក្នុងឆ្នាំ ១៩៥០ ក្នុងបណ្តាប្រជាជនអាមេរិកាំងទាំងអស់ ដែលមានចំនួន ៩៧ កន្លះភាគរយជាអ្នកចេះអក្សរ ពួកជាតិណែកមានអ្នកចេះអក្សរ ៩៦ ភាគរយ ។ ក្នុងតំបន់ទិសខាងត្បូងមានសាលាវិទ្យាល័យចំនួន ២៥០០ ខ្នងសម្រាប់ពួកស្បែកខ្មៅ ។ ក្នុងតំបន់ទិសខាងជើងពួកស្បែកខ្មៅ នឹងពួកស្បែកសបានទៅរៀនក្នុងសាលាជាមួយគ្នា ។ ក្នុងឆ្នាំ ១៩៥០ មាននិស្សិតចំនួន ១២៨.០០០ នាក់ រៀននៅក្នុងសា-លាទំសាបារមាក្ខទាំងឡាយ ហើយមានសិស្សចំនួន ១០.០០០ នាក់ តែងប្រឡងជាប់សញ្ញាប័ត្រតែរាល់ ៗ ឆ្នាំ ។ ចំនួនសិស្សជាតិស្បែកខ្មៅដែលរៀនក្នុងសា-លាបឋមវិជ្ជាជាន់ដំបូងមាន ២.២៥០.០០០ នាក់ក្នុងឆ្នាំ ១៩៥០ ។ ការសិក្សាបឋមវិជ្ជាជាន់ដំបូងក្នុងសា-លារដ្ឋការនៃរដ្ឋទាំងអស់ជាការសិក្សាខានមិនបាន , សម្រាប់កុមារទាំងឡាយទាំងស្បែកខ្មៅនឹងស្បែកស ។

សាស្រ្តាចារ្យខាងស្បែកខ្មៅជាច្រើន មិនមែនចេញមកតែពីសាលាវិសាបាមោក្ខសម្រាប់ជាតិណែកក្នុងតម្បន់ទិសខាងត្បូងប៉ុណ្ណោះទេ គឺមានចេញពីក្រុមវិជ្ជាជាន់ខ្ពស់នៃសាលាវិសាបាមោក្ខចម្រុះណាច្រើនដែរ ។ ជនជាតិណែកបានចូលធ្វើការគ្រប់ក្រសួងទាំងអស់ ហើយមានជនស្បែកខ្មៅជាច្រើន បានល្បីខាងផ្លូវសិល្បការ ។

អំពីរឿងខាងសេដ្ឋកិច្ច ពិតមែនតែពួកស្បែកខ្មៅ នៅអន់ថយជាងពួកស្បែកសប៉ុន្តែពួកស្បែកខ្មៅបានរកឃើញមានសេចក្តីចម្រើនយ៉ាងសម្បើមក្នុងរយៈពេលនៃទសវត្សខាងក្រោយនេះ ។ មានពួកស្បែកខ្មៅចំនួន ១៤ ភាគរយរកបានក្នុង ១ ឆ្នាំ ចំនួនប្រាក់ពី ១.០០០ ទៅ ១.៥០០ដុល្លា ។ ហើយក្នុងឋានៈបែបខាងលើនេះ ជាតិអាមេរិកាំងស្បែកសចំនួន ១៣ ភាគរយក៏មានសភាពដូចគ្នានឹងពួកស្បែកខ្មៅដែរ គឺថារកបានប្រាក់ប្រហែលគ្នា ។ មានការផ្សេងគ្នាយ៉ាងធំក្នុងក្រុមដែលរកប្រាក់បានក្នុង ១ឆ្នាំពី ៦.០០០ ទៅ ១០.០០០ ដុល្លា ពីព្រោះក្នុងការរកប្រាក់បានដូចរបៀបខាងលើនេះ ខាងអាមេរិកាំងស្បែកសមាន ៨ ភាគរយ ចំណែកពួកស្បែកខ្មៅមានតែ ២ ភាគរយទេ ។

ទោះបីពួកស្បែកខ្មៅ មានតែចំនួន ១០ ភាគរយនៃប្រជារាស្ត្រក៏ដោយ គឺជាតិអាមេរិកាំងកាន់បរខាងសិប្បិយការមានចំនួន១១ភាគរយ ។ នេះជាហេតុគួរឲ្យសំគាល់ពេក តើមកពីរឿងអ្វី? បាមកពីជាតិស្បែកខ្មៅតែងតែមានចិត្តបាញ់ ទៅរកខាងកសិកម្មជាងសិប្បិយការ តាំងពីកំណើតនឹងតាំងពីការហ៊ុតហាត់ជាដើមដំបូងមក ។

ឱកាសដែលនឹងធ្វើខ្លួនឲ្យចម្រើនត្រឹមត្រូវបានកើតមានដល់ជាតិស្បែកខ្មៅ ដោយសារតែការសិក្សា ។ សព្វថ្ងៃនេះមានជនជាតិណែកចំនួន ១.២៥០.០០០ នាក់ធ្វើជាសមាជិកនៃសហជីពទាំងឡាយ ព្រមទាំងកាន់កាប់ការក្នុងការិយាល័យ នៃសហជីពទាំងឡាយនោះផង ប៉ុន្តែពួកស្បែកសនៅតែមានចំនួនច្រើនជាងទោះបីនៅក្នុងតម្បន់ទិសខាងត្បូងក៏ដោយ ។ តាមបញ្ជាប់ខសន្យានៃសហជីព ពួកស្បែកខ្មៅនឹងពួកស្បែកសត្រូវទទួលប្រាក់បៀវត្សដូចគ្នា កាលណាបើកាន់កាប់មុខការដូចគ្នា ។

---

## អសោកមហារាជ (តចប់)

រកសុខដ៏ពិតប្រាកដក្នុងការបំពេញគុណ ដែលជាផ្លូវមួយនាំសត្វទៅកាន់ស្ថានសួគ៌ ។

ទី១០– របៀបសេចក្តីរុងរឿងដែលគ្មានសារប្រយោជន៍ក្នុងលោកនេះនឹងវិបាកដែលជាផលគប្បីបានទទួលក្នុងបរលោក ។

ទី១១–ប្រដៅថា ការសំដែងធម៌ នឹងការដឹកនាំ

បុគ្គលដទៃឲ្យតាំងនៅគុណធម៌និងសេចក្ដីល្អ ជាកិច្ចធំជាងកិច្ចដទៃទាំងអស់ ។

ទី១២– ប្រកាសដល់ជនដែលមិនព្រមជឿតាមថា ត្រូវបានទទួលទោស ។

ទី១៣ (សេចក្ដីខាងដើមលប់បាត់ខ្លះ អ្នកប្រាជ្ញទាំងឡាយពិចារណារកពុំទាន់ឃើញប្រាកដនៅឡើយ) សេចក្ដីខាងចុងមានមកក្នុងថ្មរៀនដែលខ្ញុំបានសរសេររួមមកខាងដើមហើយ ។

ទី ១៤ - ជាសេចក្ដីប្រមូលអត្ថបទដែលមានក្នុងគោលសិលាចារឹកទាំងអស់ ។

ព្រះបាទអសោកមហារាជ ទ្រង់ព្រះរាជបញ្ញាឲ្យតែងតាំងច្បាស់នេះហើយ ព្រះអង្គទ្រង់ប្រតិបត្តិតាមព្រះរាជាណាចរបស់ព្រះអង្គយ៉ាងហ្មឹងម៉ាត់ ដើម្បីឲ្យបានជាទិដ្ឋានុគតិដល់ជនទាំងឡាយ គឺទ្រង់សាងសាលាសម្រាប់សំណាក់ ជីកអណ្ដូង ដាំដើមឈើនៅជិតផ្លូវជាទីសញ្ចរទៅមកឲ្យជាទីកេកយដល់អ្នកដំណើរ សាងរោងព្យាបាលសម្រាប់ព្យាបាលមនុស្សនិងសត្វដែលមានជម្ងឺ សាងសួនសាធារណៈ ទ្រង់ចាត់ឲ្យមានការពិចារណាតាមផ្លូវវិទ្យាសាស្ត្រ ទ្រង់តាំងឲ្យមានភ្នាក់ងារសម្រាប់មើលសេចក្ដីសុខទុក្ខរបស់ពលរដ្ឋក្នុងផែនដីដែលជាអាណាខេត្តរបស់ព្រះអង្គ ។

ម្យ៉ាងទៀត គោលសំខាន់ដែលព្រះបាទអសោកមហារាជទ្រង់បានធ្វើគឺការបដិវត្តិវប្បធម៌របស់ជាតិអឺរ៉ុបដូចនឹងនៅថ្ងៃតទៅ:

ក្នុងសម័យនោះវប្បធម៌របស់ជាតិក្រិកបានហៀរហូរចូលមកក្នុងប្រទេសរបស់ព្រះអង្គគ្រប់ទីស្ថាន តាមលទ្ធិលោកាយតជាតិដែលព្រះបាទអាលេកសាន់ឌ័របានតាំងទុក ។ ព្រះបាទអសោកមហារាជ ទ្រង់ជ្រាបថាបញ្ហាដែលពិបាកដោះស្រាយបំផុត គឺវប្បធម៌របស់ក្រិកជាជាតិអឺរ៉ុបមានអំណាចអាចលេបអាស៊ីបាន មធ្យោបាយដែលអាចដោះស្រាយបញ្ហានេះ ដើម្បីឲ្យអាស៊ីភាគនេះតាំងនៅតទៅបាន មានតែយ៉ាងគឺត្រូវយកសីលធម៌នៃព្រះពុទ្ធសាសនាចូលតស៊ូ ព្រោះសាសនារបស់ជាតិក្រិកមិនមានអត្ថរសដែលមានសារៈជ្រាលជ្រៅដូចជាព្រះពុទ្ធសាសនាឡើយ ពួកក្រិកកាន់សាសនាដែលមានព្រះជាម្ចាស់នៃដីទឹកអាកាសជាមេលទ្ធិ មានលក្ខណៈប្រហែលគ្នានឹងសាសនាព្រាហ្មណ៍ ព្រោះហេតុនោះ ទើបព្រះបាទអសោកមហារាជទ្រង់ចាត់ឲ្យប្រកាសផ្សាយព្រះពុទ្ធសាសនានៅក្នុងប្រទេសផ្សេង ១ ដែលក្រិកបានគ្រប់គ្រង រហូតដល់ប្រទេសអេហ្ស៊ីប ក្រិកនិងម៉ាសេដូនៀ ។ ដោយហេតុព្រះពុទ្ធសាសនាជាសាសនាប្រដៅធម៌ពិតធម៌មែន មានហេតុផលគួរជឿបាន ទើបពួកក្រិកជាច្រើនព្រមទទួលរាប់អានគោរពព្រះពុទ្ធសាសនា ព្រមទាំងចេញបួសជាភិក្ខុរាងង ៗ មានព្រះអរហន្ត១អង្គជាតិក្រិក កើតក្នុងត្រកូលក្សត្របានបួសក្នុងព្រះពុទ្ធសាសនា ប្រតិបត្តិតាមពុទ្ធោវាទបានសម្រេចព្រះអរហត្តផល នាមដើមមិនប្រាកដ តែដែលបួសហើយ

មាននាមថា ធម្មវឌ្ឍិត ព្រះអហាទូអគ្គនោះជាទីស្រឡាញ់រាប់អានរបស់ព្រះបាទអសោកមហារាជណាស់ នេះសំដែងឲ្យឃើញថាព្រះបាទអសោកមហារាជព្រះអង្គមិនមែនមានគុណចំពោះព្រះពុទ្ធសា-សនាតែប៉ុណ្ណោះទេ ព្រះអង្គមានគុណដ៏លើសលប់ដល់ទ្វីប ដោយទ្រង់ប្រើមធ្យោបាយយ៉ាងល្អ យកព្រះពុទ្ធសាសនាមកកំរិងការពារមិនឲ្យសាបសូន្យទៅបាន ។

ក្នុងបច្ចិមភាគនៃព្រះជន្មាយុ ព្រះបាទអសោកទ្រង់បរិច្ចាគទានយ៉ាងលើសលប់ ទាល់តែពួកសេនាបតីជំទាស់មិនព្រមអនុវត្តន៍តាម ព្រោះក្រែងអស់ព្រះរាជទ្រព្យ សម្រាប់ចំណាយក្នុងផ្ទៃរាជការ ទីបំផុតទ្រង់អនុសិទ្ធិរាជ ឲ្យស្ដីទីរាជការតំណាងព្រះអង្គ ក្នុងកាលដែលព្រះអង្គទ្រង់ទិវង្គតប្រមាណ ២-៣ ឆ្នាំ ។

ព្រះបាទអសោកទ្រង់ទិវង្គតក្នុងក្រុងតក្កសិលា ឆ្នាំដែលទ្រង់ទិវង្គតនោះ ប្រវត្តិសាស្ត្រមិនបានពោលប្រាកដ តែមានសេចក្ដីដំណាលខ្លះចារិកទុកថា ក្នុង ព.ស. ៣១១ ខ្លះថា ៣១៤ ក្នុងច្បាប់ខ្លះពោលថា ព្រះបាទអសោមហារាជទ្រង់ទិវង្គតក្នុងឆ្នាំពុទ្ធសករាជ ៣១៧ ។

តាមប្រវត្តិសាស្ត្រដំណាលថា ក្នុងកាលដែលព្រះអគ្គមហេសីដែលជាព្រះរាជជននីនាថរបស់ព្រះមហិន្ទ: នឹងព្រះនាងសង្ឃមិត្តាទិវង្គតទៅ ព្រះបាទអសោកមហារាជទ្រង់មានព្រះអគ្គមហេសី ២ ព្រះអង្គទៀតព្រះនាមករុវ៉ាគី (ឬការុវាគី) មានព្រះរាជបុត្រព្រះនាម(តីវរ:) នឹងព្រះនាងអសន្ធិមិត្រ (ឬអសន្ធិមិត្តា) មានព្រះរាជបុត្រព្រះនាមថា កុនាល: ។ កាលព្រះនាងសន្ធិមិត្រសោយព្រះវិលាល័យទៅ ព្រះអង្គទ្រង់មានមហេសីថ្មីមួយអង្គទៀត ព្រះនាមថា តិស្សរក្សិត: (ឬតិស្សរក្ខា) ទ្រង់តាំងក្នុងដំណែងជាអគ្គមហេសី តែព្រះនាងតិស្សរក្សិត: ជាស្ត្រីអាក្រក់មិនមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា មានសេចក្ដីប្រាថ្នាអសទ្ធម្មនឹងកុនាលកុមារ ព្រោះកុនាលកុមារមានព្រះនេត្រល្អដូចភ្នែកម្រឹគ តែកុនាលកុមារពុំមានព្រះទ័យស្ម័គ្រស្និទ្ធជាមួយឡើយ ហើយទ្រង់ពិរោធខ្លាំងទៅលបគិតគូជាមួយនឹងពួករាជបរិពាររបស់ព្រះបាទអសោក ឲ្យចាប់ព្រះកុនាលកុមារ ខ្វេះយកព្រះនេត្រចេញហើយសម្លាប់ចោល តែព្រះកុនាលកុមារទ្រង់គៀសព្រះអង្គទៅបាន ។ ព្រឹត្តិការណ៍នេះមិនស្ងប់ស្ងាត់ បានជ្រាបទៅដល់ព្រះបាទអសោកមហារាជ ទើបទ្រង់ព្រះរាជបញ្ជាឲ្យចាប់នាងតិស្សរក្សិត:ព្រមទាំងអ្នករួមគំនិតទាំងអស់មកដុតភ្លើងឲ្យឆេះទាំងរស់ ។ មុនដែលទ្រង់ទិវង្គតពេល ២ ឆ្នាំ ព្រះបាទអសោកទ្រង់ស្ដេចចេញប្រព្រឹត្តវត្ត (រក្សាសីល) ដរាបដល់កាលកំណត់ព្រះជន្មវស្សាក៏ទ្រង់ក្ស័យព្រះជន្ម ។

លុះព្រះបាទអសោកទ្រង់ទិវង្គតហើយព្រះរាជឱរសរបស់ព្រះអង្គទ្រង់ព្រះនាមជលទក: ទ្រង់បានសោយរាជ្យតវង្សព្រះបិតាក្នុងក្រុងកស្មីរ: តែព្រះរាជាអង្គនេះទ្រង់បែរទៅឧបត្ថម្ភសាសនាព្រាហ្មណ៍វិញ ទ្រង់ដេញ

ពួកពុទ្ធសាសនិក (អ្នកកាន់ព្រះពុទ្ធសាសនា) ឲ្យចេញចាកដែនអស់ ប្រឆាំងនឹងព្រះរាជឧបាយព្រះបាទអសោក តែទោះបីយ៉ាងណាក៏ដោយ ក៏ព្រះរាជឧបាយរបស់ព្រះបាទអសោក ក៏នៅតែមិនសាបសូន្យឡើយ ផលដែលទ្រង់បានឧបត្ថម្ភ ដល់ព្រះពុទ្ធសាសនាមកហើយនោះ ពិតមែនជាមិនបានគង់នៅជាស្ថាពរក្នុងវង្សរបស់ព្រះអង្គ ប៉ុន្តែបានទៅគង់នៅចាក់ឫសជាប់មាំមួនក្នុងប្រទេសដទៃ ៗ ធ្វើឲ្យព្រះពុទ្ធសាសនារុងរឿងក៏ខ្លាំងយ៉ាងទូលំទូលាយក្នុងនានាប្រទេសដូចបានបរិយាយមក ។

សព្វថ្ងៃកិត្តិគុណរបស់ព្រះបាទអសោកមហារាជ នៅតែល្បីល្បាញខ្ចរខ្ចាយសាយសុះសព្វតាំងពីអាស៊ីភាគខាងលិចទៅទល់នឹងអាស៊ីភាគខាងកើតដែលមានប្រទេសជប៉ុនជាទីបំផុត អ្នកប្រវត្តិសាស្ត្របានថ្លែងសរសើរថា ព្រះបាទអសោកមហារាជជាផ្កាយមួយដួងដែលភាឺរស្មីស្រស់មានសេចក្តីភ្លឺពេញទិសទីគ្រប់ទាំងអនាគតដ៏វែង ដោយមិនមានសៅហ្មងក្នុងថ្ងៃណាមួយឡើយ ។

មហា ឆ្នុត-ទិម

---

# រឿងតុក្កតាធ្វើពីទធិជាតិ

តពីលេខ ១០ មក

## ព្រះករុណាទ្រង់យាងត្រឡប់

នាវាទាំងប្រាំពីរដែលហែតាមព្រះមហាក្សត្របានធ្ងន់កាត់សមុទ្រទាំងប្រាំពីរនឹងខន្ទដប់បី[1] ក្នុងរយៈវេលាប្រាំមួយខែមកហើយទ្រង់មានព្រះរាជបំណងចង់យាងត្រឡប់មកកាន់ព្រះរាជនិវេសនដ្ឋានព្រមទាំងខ្សែមាសត្បូងទទឹម, ឱប៉ុរៈ, មាស, កងកដខ្សែនិងសំពត់សារីវិសេសសម្រាប់ព្រះរាជនីទៅ ។

*

* *

តែក្នុងមួយរំពេចព្រះមហាក្សត្រទ្រង់ព្រះតម្រិះនឹកឃើញដល់បណ្តាំព្រះរាជនីទុកពីសូមឲ្យទ្រង់ផ្ញើកូនស្វាតូចមួយ ។

ទ្រង់ត្រាស់បង្គាប់ឲ្យហៅនាយករដ្ឋមន្ត្រីមក ហើយទ្រង់មានព្រះបន្ទូលថា: លោកនាយក, យើងមានកំហុសជាធំហើយ ដោយយើងមិនបានទិញកូនស្វាសម្រាប់ព្រះរាជនីឲ្យផង ចូរលោកអញ្ជើញទៅបំពេញកិច្ចនោះចុះ ។

ហើយលោកនាយករដ្ឋមន្ត្រីក៏បានអញ្ជើញទៅស្វែងរកកូនស្វាមួយមានមុខដូចក្មេងនេះ ។

ព្រះមហាក្សត្រទ្រង់គង់លើព្រះទីនាំងគជេន្ទ្រស, ទ្រង់កាត់ប្រជារាស្ត្រជាច្រើនសម្បើមអស្ចារ្យមកទទួលព្រះអង្គជាព្រះរាជកិត្តិយស ទ្រង់យាងតាមមហាវិថីហូងទៅដល់ព្រះបរមរាជវាំង ។ ទ្រង់កាន់គ្រឿងមាសនឹងព្រះពស្ត្រសារី, យាងចូលទៅក្នុងព្រះរាជដំណាក់ប្រាំពីរជាន់ ហើយទ្រង់ប្រញាប់ប្រញាល់ចូលទៅខាងបន្ទប់ព្រះនាងសុខរាត្រីជាព្រះរាជសំណប់

---

[1] ពាក្យមានន័យថាទំហុំធំវែងឆ្ងាយទូលាយដែលគួរធ្វើដំណើរ ។

របស់ព្រះអង្គ ។

នៅខាងលើថ្នាក់ទីប្រាំពីរនៃព្រះបរមរាជវាំង, ព្រះនាងសុខវតីទ្រង់គង់នៅពីមុខកញ្ចក់មាស ព្រះនាងកួតសក់វែងទីងក្រាស់មាសហើយអង្គាញបង់ទឹងម្ជុលមាសព្រមទាំងសំណាញ់មាសគ្របសក់ (Résille) រួចព្រះនាងទ្រង់បើកប្រអប់មាស យកម្សៅក្រហមសិន្ទូរ (Sindour)(១) មកលាបថ្ងាស់ហើយទឹងខសថកជ័ល (Kajal) (២) មកលាបចិញ្ចើមវែង...រួចព្រះនាងបានគូសជុំវិញជើងនូវគំនូរអ័លតា (Alta) ពណ៌ទាំងប្រាំពីរ យេនាក់ចោមរោមជាបរិវារទីខ្លះកាន់ថាសមាស សម្រាប់ដាក់កម្រងបុប្ផា, ខ្លះកាន់ប្រអប់ពានៈ(៣) (pânes) ។

## ព្រះនាងសុខវតីទទួលព្រះមហាក្សត្រ

ព្រះមហាក្សត្រទ្រង់បានចូលទៅក្នុងព្រះតំណាក់ព្រះនាងសុខវតីទ្រង់គង់ជិតព្រះនាង នៅលើគ្រឡាព្រះគំនាល់ធ្វើពីថ្មកែវហើយមានព្រះបន្ទូលទៅកាន់ព្រះនាងសុខវតីថា :

"នៅប្រទេសត្បូងទទឹមក្លាត (ជណ្តើរ) សុទ្ធតែត្បូងទទឹមហើយថ្កល់ទាំងអស់គ្រាលដោយត្បូងទទឹមដែរ បងបានយកពីប្រទេសក្រហមប្រាលនូវខ្សែដៃមាសសម្រាប់ពាក់ដៃនាង ។ ចូរនាងយកខ្សែដៃមាសនេះចុះ" ។

នៅប្រទេសមាស, ជណ្តើរសុទ្ធតែមាសសូម្បីខ្លាចក៏ជាមាសដែរ ។ បងបានយកពីប្រទេសក្ងួសខ្មៅនូវនុប៉ុរៈមាសឲ្យពាក់កជើង ។ ចូរនាងយកនុប៉ុរៈមាសនេះចុះ ។

នៅប្រទេសគជខ្សែ មានលលកពីរជើងរាជគជខ្សែបំពាក់ត្បូងទទឹម ។ លលកនេះពងគជខ្សែរាល់ព្រឹករាល់ល្ងាចព្រះរាជនីនៅប្រទេសគជខ្សែទ្រង់យកពងនោះមកធ្វើជាកម្រង; ពេលយប់ព្រះនាងទ្រង់យកទៅបង្ក្លាប់នឹងព្រះកេសា ហើយរាល់ព្រឹកទ្រង់បោលកម្រងនោះទៅឆ្ងាយ ។ បងបានយកពីប្រទេសនេះនូវខ្សែព្រះសុរង់គជខ្សែ មកបំពាក់កងពណ៌លឿងដូចមាស ។ ចូរនាងយកខ្សែព្រះសុរង់នេះទៅពាក់ចុះ ។

នៅប្រទេសត្បូងកណ្តៀងខៀវមានព្រះរាជបុត្រីមួយអង្គទ្រង់ត្បាញសំពត់ដ៏សូត្រខៀវផ្ទៃមេឃ ។ ទ្រង់គង់រាល់យប់នៅលើកទហាលក្រាលត្បូងកណ្តៀងខៀវហើយព្រះនាងត្បាញសំពត់សារីខៀវសម្រាប់គ្រងតែម្តង ដើម្បីនឹងស្តេចទៅកាន់បូជនីយដ្ឋាននៃព្រះនិលកណ្ឋ ។ បងបានបង្គាប់ឲ្យយកនាគប្រាំពីរផ្ទុកពេញដោយមាសបូរនឹងសំពត់សារីខៀវស្រាល ; ឱព្រះនាងចូរមើលរបស់ដែលបងយកមកឲ្យ; បងបានធ្វើដំណើរទៅតាមពិភពលោកក៏ព្រោះតែនាង; បងបានទៅតាមភូមិភាគជិតនឹងប្រទេសឆ្ងាយក៏ព្រោះ

(១) សិន្ទូរ (Sindour) ម្សៅក្រហមដែលស្ត្រីជាភរិយាយកទៅគូរលើថ្ងាសជាសុភមង្គល ។ ២ កជ័លៈ ខសថមួយបែបសម្រាប់ដាក់ភ្នែក ។ ៣ ពានៈ គឺសន្លឹកខៀវណាយរំដោយស្លា, ម្លូនិងគ្រឿងទេសដែលគេបរិភោគដើម្បីឲ្យបបូរមាត់ក្រហមព្រាល ។

តែនាង ហើយបងបានយកគ្រឿងប្រដាប់តែងកាយនិងសំពត់សារីដែលសមរម្យឲ្យនាងពាក់" ។




ព្រះរាជទេវីសុខវតីបានយកខ្សែដៃទាំងប្រាំបីគូពាក់ដៃទាំងពីរ ។ តែ...ខ្សែដៃត្បូងទទឹមពីជាន់កដៃនាងគេគាបទាញឡើងទៅដល់ស្មាព្រះនាងបាន... ។

រួចព្រះនាងបានយកខ្ទុំរមាសទាំងជប់គូយកមកពាក់កជើងនាងតែខ្ទុំរនោះធំជាងកជើងនាង ជ្រុះទៅលើខ្នងជើង.... ។

ព្រះនាងទ្រង់ស្ទុះទៅបន្តិចហើយខ្ទុំរនោះក៏ធ្លាក់ចុះទៅដល់ដី ..... ។

ក៏ក្រោកព្រះទីក្រញូវមិនពេញព្រះទ័យ...ព្រះនាងទិយកខ្សែកពាក់ជុំវិញក, តែខ្សែកដែលយកមកពីប្រទេសគជខ្សែងនោះតូចចង្អៀតពន់ពេកធ្វើឲ្យរលាកស្បែកព្រះនាង!.... ។

ព្រះរាជទេវីមានព្រះទ័យទោមនស្សជាខ្លាំង ....

ព្រះនាងបានយកព្រះពស្ត្រសារីមកបត់ជាប្រាំពីរផ្នត់ ហើយទ្រង់គ្រង....តែសារីនៅវែងមេឃទ្វេទីបពេក .....

ព្រះនាងទ្រង់សោយសោកាហើយទ្រង់គ្រោធជាខ្លាំង ; ព្រះនាងទ្រង់កន្ត្រាក់ខ្សែដែលមានដាំត្បូងទទឹមប្រាំបីពាន់, ទាត់នឹងព្រះបាទនូវខ្ទុំរមាសទាំងជប់គូ, បោះបោលចោលឆ្ងាយនូវខ្សែកគជខ្សែងនិងព្រះស្ត្រសារីហើយស្រែកថា: " តើឲ្យស្លៀកទ្រូមពន់ពេក, គ្រឿងប្រដាប់តែងកាយព្រមទាំងសំពត់សារីនេះ ! តើព្រះអង្គម្ចាស់ទ្រង់យកជុំត្រួសមកដាក់លើខ្សែដៃការក្រកម្ដេចនេះ? ខ្ទុំរនេះធ្វើនឹងជង្គង់ស្លាសក្រក់ក្រៃលែងណាស់ក្រក់? ខ្សែកគជខ្សែងនេះដែលស្ដេចឲ្យពាក់រួចហើយ! ហើយសំពត់សារីនេះ ដែលគេប្រមូលយូរយារណាស់មកហើយ! ។ បើកាលណាខ្ញុំម្ចាស់ នៅមើលឃើញវត្ថុទាំងអស់នេះ ចិត្តខ្ញុំម្ចាស់ពេញដោយការខ្ពើមរអើមពន់ពេកបើកាលណាខ្ញុំម្ចាស់ពាក់នូវវត្ថុទាំងនេះ, ចិត្តខ្ញុំម្ចាស់អៀនខ្មាសជាយ៉ាងក្រៃលែង ។ សូមព្រះអង្គទ្រង់យកវត្ថុទាំងនេះចេញឆ្ងាយពីខ្ញុំម្ចាស់ ខ្ញុំម្ចាស់មិនព្រមទទួលនូវគ្រឿងមាសចាស់ឬសំពត់សារីចាស់នេះទេ ។

ព្រះរាជទេវីទ្រង់អន់ព្រះទ័យពន់ពេក, រត់ទៅសម្ងំគង់បន្ទប់បំពេញសេចក្តីទោមនស្សយ៉ាងក្រៃលែង(១) ។

(១) បន្ទប់ទោមនស្សៈគឺបន្ទប់មួយដូចដែលព្រះមហាក្សត្រឬព្រះអគ្គមហេសី ទ្រង់ចូលទៅគង់ក្នុងពេលកំពុងខ្ញាល់ ។

ព្រះមហាក្សត្រទ្រង់មានព្រះភ័ក្ត្រស្វាយ...ទ្រង់បានយកគ្រឿងអលង្ការនឹងសំពត់សារី (តម្លៃនាវាប្រាំពីរផ្ទុកពេញទៅដោយមាស) ហើយទ្រង់យាងដោយសន្សឹមទៅកាន់មន្ទីរមហាសន្និបាត ។

## សត្វស្វាចេញមក

នាយករដ្ឋមន្ត្រីបានធ្វើដំណើរទៅតាមផ្លូវហើយពិនិត្យរកគេហដ្ឋាននៃព្រះរាជអាណាចក្រ បានអញ្ជើញទៅដល់នាវាមួយដែលទើបនឹងមកពីប្រទេសនៃគ្រូមន្តអាគមស្រាប់តែប្រទះនឹងកូនស្វាមួយមានមុខដូចជាពោលក្មេង ។

លោកបានទិញកូនស្វានោះតម្លៃ១គូប្រ៊ី(Covorie)(១) ហើយនាំទៅកាន់ព្រះបរមរាជវាំង ; លោកបានរង់ចាំព្រះមហាក្សត្រទ្រង់ នឹងយាងមកកាន់មន្ទីរមហាសន្និបាត, ប្រុបដើម ព្រះស្វេតច្ឆត្រ, ក្នុងទីកៀនមួយ.... ។

*
* *

ព្រះមហាក្សត្រទ្រង់យាងទៅដល់ទីនោះមានព្រះបន្ទូលទៅកាន់រដ្ឋមន្ត្រីទាំងឡាយថា: "យើងខ្ញុំមានចិត្តខ្វល់ពន់ពេក, គ្រឿងប្រដាប់ដែលយកមកធំពន់ពេក ហើយសំពត់សារីខ្លីពេក, ព្រះនាងស៊ុខពន់ពាក់មិនបាន; តែខ្ញុំបានរក្សាយ៉ាងមធ្យមណាស់ដែរ ។

ក្នុងពេលនោះស្វាក៏ទៅចំព្រះភ័ក្ត្រព្រះមហាក្សត្រ ហើយ ថ្វាយបង្គំព្រះអង្គរួចក្រាបទូលទ្រង់ថា:

(នៅមានត)

(១) គូប្រ៊ីៈខ្ចៅតូចៗ សម្រាប់ប្រើជារូបិយវត្ថុ ។



# ប្រវត្តិខេត្តបាត់ដំបង

តពីលេខ ៣១ មក

បរិភោគទៀត ពេលបរិភោគរួចព្រំកិលមានកម្លាំងយ៉ាងខ្លាំងខ្លា ស្មើនឹងដំរីសារ ៧ តមកទៀត ព្រះអង្គម្ចាស់ព្រំកិលរើយាមនោះមើលទៀត ក៏បានឃើញច្បាស់នូវប្រដាប់សម្រាប់អ្នកមានបុណ្យ ទើបព្រះអង្គម្ចាស់សន្និដ្ឋានក្នុងចិត្តបានថា ព្រះអង្គហ្នឹងហើយដែលអាចទទួលយកនូវប្រដាប់ទាំងនោះបាន ។

ព្រះរាជកុមារព្រំកិលដែលយើងបានពណ៌នាមកនេះ ក៏យើងគួរពិចារណាមើលភាពដើមរបស់ព្រះអង្គម្ចាស់មានភាពមិនគួរនឹងមានឋានៈបានប៉ុណ្ណោះទេ គេឃើញរាជកុមារកកិលចេញពីអាពមមកក្នុងពេលថ្ងៃនេះសោះ មិនទាន់តែរំលងវេលាបានយូរប៉ុន្មានផង ព្រះរាជកុមារក៏សត់ហើយពិការផង ក៏ក្លាយបានជាក្សត្រមួយអង្គយ៉ាងអស្ចារ្យ ទ្រង់ហោះកាត់អាកាសដោយអាជានេយ្យសេះ ចេញពីទិសព្ទៀសានសំដៅព្រះរាជវាំងព្រះចៅដំបងក្រញូងក្នុងពេលដែលប្រជារាស្ត្រកំពុងតែលើកអញ្ជលីបង្គំគ្រប់ៗគ្នា; ស្ដេចដំបងក្រញូងដែលព្រះអង្គប្រុងខ្លួនទឹងធ្វើចម្បាំងតអ្នកមានបុណ្យ ទ្រង់បានឈរចាំនៅមុខប្រាសាទ, កាលបើទ្រង់ឃើញព្រះរាជកុមារព្រំកិលកំពុងជិះសេះសេះហោះមកយ៉ាងនេះ ទ្រង់ក៏ចាប់យកដំបងវិសេសរបស់ទ្រង់ចោលសំដៅទៅព្រះរាជកុមារព្រំកិល តែអំណាចតេជានុភាពរបស់រាជកុមារ ធ្វើឲ្យដំបងវិសេសនោះរត់ផុតហួសទៅធ្លាក់នៅជិតត្បូងសង្កែហើយក៏បាត់នៅទីនោះទៅ បានជាមានពាក្យអ្នកស្រុកហៅថា បាត់ដំបង, ស្រុកសង្កែៗ

ស្ដេចដំបងក្រញូងកាលបើឃើញហេតុដូចនោះហើយ ក៏យល់ថាព្រះអង្គមានតេជអំណាចទន់ខ្សោយជាងគេ ទ្រង់ក៏ភៀសព្រះអង្គចាកព្រះរាជវាំង ទៅគង់នៅទីក្រុងឡាលុង (ប្រទេសលាវ) ហើយក៏ទិវង្គតនៅទីនោះ ដូចមានព្រះចេតិយបញ្ចុះព្រះអង្គនៅទីនោះស្រាប់ ។

បំណែកព្រះនាងកែវដែលមានគភ៌ទ្រង់នៅទីង គាគាហេយាយលាក់នេះលុះគ្រប់ទសមាសក៏ប្រសូតព្រះរាជបុត្រមួយព្រះអង្គ គបដោយរូបសម្បត្តិនឹងលក្ខណៈយ៉ាងប្រពៃ ថែមទាំងមានលាយល័ក្ខនៅព្រះហស្តនឹងព្រះបាទនៃរាជកុមារផង; ព្រះរាជកុមារតូចនេះមាននាមថាបក្សីចាំក្រុង ដោយព្រះរាជកុមារទទួលអារក្ខាពីបក្សីនៅទីវាលស្រែ ។

ប្រវត្តិឈ្មោះនៃខេត្តបាត់ដំបង ដែលខ្ញុំបានយកមកនិពន្ធក្នុងលើកនេះ ក៏សន្និដ្ឋានថាចប់ដោយសេចក្ដីខ្លីៗ

ដោយខេត្តបាត់ដំបង មានការទាក់ទងប្រវត្តិសាស្ត្រសំខាន់ ច្រើនកន្លែងក៏គួរតែខ្ញុំបាច់រៀបរាប់ពីប្រវត្តិសាស្ត្រខេត្តនេះតទៅទៀត ។ ប្រវត្តិសាស្ត្រនោះនឹងចែកចេញជា ៧ កាល

កាលទី ១ ពី គ.ស. ៥៥០ ទៅដល់ ៨២០

-២- ៨២០ - ១៣០០

-៣- ១៣០០ - ១៧៩៥

-៤- ១៧៩៥ - ១៩០៧

-៥- ១៩០៧ - ១៩៤៤

-៦- ១៩៤៤ - ១៩៤៦

-៧- ១៩៤៦ -ដល់មកសម័យបច្ចុប្បន្ននេះ ។

# ព្រះរាជដំណើរវិលត្រឡប់

ក្រោយពីព្រះរាជទស្សនកិច្ចនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងអស់រយៈពេលមួយសប្ដាហ៍ ស្ដេចបានយាងត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ នៅថ្ងៃចន្ទទី២២វិច្ឆិកាឆ្នាំ១៩៥៤; ម៉ោង១៣,៣០នាទី អាកាសចរទេមរត្ថមិន្ទ បាននាំព្រះអង្គមកដល់ចំណតអាកាសយានពោធិចិនតុង ក្នុងឱកាសនោះគេឃើញអ្នករាជការធំ-តូច ព្រមទាំងអង្គទូតគ្រប់ៗឋានៈមួយអន្លើដោយប្រជារាស្ត្រលំបមុឺន បានទៅរង់ចាំទទួលព្រះអង្គមិនដោយមិនគិតដល់កំដៅនៃព្រះអាទិត្យសោះ ក្នុងពេលនោះគួរឲ្យអស្ចារ្យណាស់ ប្រជាជននៅក្នុងព្រះរាជធានីទាំងមូល មិនអាចរាប់ចំនួនបានទេ ដោយអំណាចព្រះបារមីដ៏វិសេសរបស់ព្រះអង្គ ត្រូវតែមកជួបគ្រប់ឋានៈចេញទៅរង់ចាំគោរពព្រះករុណាទំគុណឈរប្រជ្រៀតណែនណាន់ តាំងតាមបណ្ដោយតាំងពីចំណតអាកាសយានពោធិចិនតុងរហូតមកដល់ព្រះបរមរាជវាំង, តាមវិថីដែលព្រះរាជាស្ដេចទ្រង់យាងគេឃើញទាំងសំពត់ថែលចារិកអក្សរសរសើរព្រះរាជកេតុ និងព្រះពុទ្ធករណីយកិច្ច ចំពោះមាតុប្រទេសបណ្ដែតតាមផ្លូវរហូតដល់ព្រះរាជវាំងចតុមុខ ។ ល ។

## ប្រទេសកម្ពុជាត្រូវខាតវីរជនមួយរូប

ឯ.ឧ.ចាន់-ណាក ជាអតីតនាយករដ្ឋមន្ត្រីបានទទួលមរណភាពក្នុងករណីយជាប្រធាននៃសន្និសីទបតុភាគីនាក្រុងប៉ារីស នៅមន្ទីរពេទ្យបាលពេតឯប្រទេសបារាំង កាលពីថ្ងៃទី៧វិច្ឆិកាឆ្នាំ ១៩៥៤, បាននាំសពឯ.ឧ.មកដល់រាជធានីភ្នំពេញតាមអាកាសយាន នៅថ្ងៃ ១០-១១-៥៤ បានរៀបចំបូជា យ៉ាងឧឡារិកក្រោមកិច្ចចាត់ចែងនៃរាជរដ្ឋាភិបាល កាលពីថ្ងៃ ២៤-១១-៥៤ ។

សមាគមមិត្តសាលាបាលី សូមរំលែកសេចក្ដីទុក្ខសោកដ៏គានតឹងពីរាជរដ្ឋាភិបាល និងគ្រួសារទាំងសូមឧទ្ទិសដល់វិញ្ញាណខន្ធរបស់ ឯ.ឧ. សូមឲ្យអញ្ជើញមកយកកំណើតក្នុងកម្ពុជប្រទេសយើងទៀត ។